00910680

លេខ: D122/6

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 17 / 05 / 2013

ម៉ោង (Time/Heure): 14:20

...សំណុំរឿង/Case File Officer/L'agent chargé ... SANN RADA

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**លេខសំណុំរឿង: ០០៤/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស**

ចំពោះមុខ ៖ **ចៅក្រម យូ ប៊ុនឡេង**
**ចៅក្រម Mark B. HARMON**

កាលបរិច្ឆេទ ៖ **ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣**

ភាសាដើម ៖ **អង់គ្លេស**

ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ**

# ដីកាសម្រេចលើញត្តិ និងសារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី

**<u>ផ្ញើជូន</u>**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Annie DELAHAIE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Philippine SUTZ

**<u>ចម្លងជូន៖</u>**

**ភាគីដាក់សំណើ**
លោក មុំ លុជ្យ
លោក Goran SLUITER
លោក Richard ROGERS

**ប្រធានអង្គភាពគាំពារការពារក្តី**
លោក Isaac ENDELEY

**អនុប្រធានការិយាល័យរដ្ឋបាល**
លោក Knut ROSANDHAUG

1. **បានឃើញ** កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការវិនិច្ឆ័យទោសនៅក្រោមច្បាប់កម្ពុជាទៅលើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក")។

2. **បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

3. **បានឃើញ** វិធាន ១១, ២១, ២២, ៥៥, ៥៧, និង ៧២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក វិសោធនកម្មលើកទី ៨ (វិធានផ្ទៃក្នុង)។

4. **បានឃើញ** មាត្រា ១, ២, ៥, ៧ និង៩ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី ("បទបញ្ជារដ្ឋបាលរបស់ អ.គ.ក")។

5. **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទងនឹងសំណុំរឿង០០៤[១] ដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង កាលពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[២]។

6. **បានឃើញ** ការបើកកិច្ចស៊ើបសួរទាក់ទងនឹងបទចោទប្រកាន់អំពីការរំលោភបំពានលើ**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦** ការរំលោភបំពានលើ**អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍** និង**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៤, ៥, ២៩(ថ្មី) និង៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ព្រមទាំងមាត្រា ២០៩, ២១០, ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧, និង ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦) ។

---

[១] សំណុំរឿង ០០៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។

[២] សំណុំរឿង ០០៤ ឯកសារ D1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

00910682



7. **បានឃើញ** លិខិតរបស់សហចៅក្រមស៊ើបអង្កេត ស្តីពី*សិទ្ធិការពារក្តីនៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០[៣]។

8. **បានឃើញ** *ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ ០០៣ និង ០០៤* ចេញដោយសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១[៤]។

9. **បានពិចារណាទៅលើ** *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឯកសារ D110[៥]) និង *ដីកាសម្រេចទទួលស្គាល់មេធាវី* ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២ (ឯកសារ D111/5[៦] "*ដីកាសម្រេចទទួលស្គាល់*") ចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង (ស.ច.ស.អ.ប) Laurent Kasper-Ansermet ។

10. **បានឃើញថា** នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ និងថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Harmon បានចុះហត្ថលេខាលើកំណត់ហេតុនៃករណីខ្វែងយោបល់គ្នាពាក់ព័ន្ធ ដូចជាបញ្ហានេះ។

11. **បានឃើញថា** *សេចក្តីសម្រេចលើសំណើបន្ទាន់សុំបន្ថែមចំនួនទំព័រសម្រាប់ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៣ (ឯកសារ D122/1[៧])។

---

[៣] សំណុំរឿង ០០៤ ឯកសារ A1/2 *ចម្លើយតបរបស់ ស.ច.ស ស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ ។

[៤] សំណុំរឿង ០០៤ ឯកសារ D4/1 *ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ។

[៥] សំណុំរឿង ០០៤ ឯកសារ D110 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២។

[៦] សំណុំរឿង ០០៤ ឯកសារ D111/5 *ដីកាសម្រេចទទួលស្គាល់មេធាវី* ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២។

[៧] សំណុំរឿង ០០៤ ឯកសារ D122/1 *សេចក្តីសម្រេចលើសំណើបន្ទាន់សុំបន្ថែមចំនួនទំព័រសម្រាប់ ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៣។

12. **បានពិចារណាទៅលើ** *ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ដែលត្រូវបានដាក់ដោយលោក មុំ លុជ្ស លោក Richard Rogers និងលោកGoran Sluiter (“*ភាគីដាក់សំណើ*”) ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ (ឯកសារ D122/2 “*ញត្តិស្តីពីសិទ្ធិក្នុងការមានមេធាវី*”)[៨]។

13. **បានពិចារណាទៅលើ***សារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ដែលត្រូវបានដាក់ដោយភាគីដាក់សំណើ នៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៣ (ឯកសារ D122/5[៩])។

## ការពិភាក្សា

### ទឡ្ហីករណ៍របស់ភាគីដាក់សំណើ និងសំណើ

14. *ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ដាក់ដោយភាគីដាក់សំណើ លើកឡើងថា “*ជនសង្ស័យមានសិទ្ធិទទួលបានការការពារប្រកបដោយប្រសិទ្ធភាព តាមរយៈមេធាវីអន្តរជាតិដែលគាត់បានជ្រើសរើសដោយខ្លួនឯង ដោយមិនមានការជ្រៀតជ្រែកដោយអយុត្តិធម៌ពីមន្ត្រីរដ្ឋបាលរបស់តុលាការ*” ដូច្នេះហើយទើប ស្នើសុំឱ្យ ស.ច.ស “*បង្គាប់ការិយាល័យរដ្ឋបាល “OA [ក.រ]”រួមទាំងអង្គភាពគាំពារការពារក្តី“DSS[អ.គ.ក]”រៀបចំកិច្ចសន្យាសេវាផ្លូវច្បាប់សម្រាប់លោក Richard Rogers (“Rogers”) ក្នុងនាមជាមេធាវីអន្តរជាតិសម្រាប់ការពារក្តីឱ្យជនសង្ស័យ*”[១០]។

15. សំណើនេះគឺមានមូលដ្ឋានផ្អែកលើការអះអាងដែលថា ទាំង អ.គ.ក និង ក.រ “បានប្រមាថទៅលើ”ដីកាសម្រេច ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២ ដែលក្នុងនោះ “*សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Laurent Kasper-Ansermet (“RICIJ [ស.ច.ស.អ.ប]”* បានចេញ

---

[៨] សំណុំរឿង ០០៤ ឯកសារ D122/2 *ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣។

[៩] សំណុំរឿង ០០៤ ឯកសារ D122/5 *សារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៣ ។

[១០] សំណុំរឿង ០០៤ ឯកសារ D122/2 *ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ២។

*ដីកាសម្រេចទទួលស្គាល់មេធាវី ("ដីកាសម្រេចទទួលស្គាល់" ដោយប្រកាសថាលោក Rogers "ត្រូវបានជនសង្ស័យជ្រើសរើស និងជួលជាមេធាវីយ៉ាងត្រឹមត្រូវ"* និងបានបង្គាប់ឱ្យ ក.រ និង អ.គ.ក *"ទទួលស្គាល់ការតែងតាំង[...]លោក Rogers"* និងផ្តល់ឱ្យ *"លោក Rogers នូវធនធានចាំបាច់ដើម្បីធានាការតំណាងប្រកបដោយប្រសិទ្ធភាព"*[១១]។

16. *សារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ដែលត្រូវបានដាក់ដោយភាគីដាក់សំណើ បញ្ជាក់ថា ឯកសារថ្មីៗដែលពេលថ្មីៗនេះត្រូវបានបង្ហាញជូនមេធាវីរបស់ [redacted] លើកឡើងពីអង្គហេតុថ្មីៗ ដែលពួកគាត់មិនបានដឹង នៅពេលដែលពួកគាត់បានដាក់ *ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣។

17. យោងតាមសារណាបន្ថែមនេះ អនុប្រធានការិយាល័យរដ្ឋបាល(អ.ប.ក.រ)Knut Rosandhaug បានព្យាយាមដោយចេតនាធ្វើឱ្យ ស.ច.ស មានការយល់ច្រឡំទាក់ទងនឹងដំណើរការជ្រើសរើស និងចាត់តាំងលោក Rogers ជាសហមេធាវីបរទេស។ សារណាបន្ថែមនេះ ក៏បញ្ជាក់ទៀតថា អ.ប.ក.រ និងប្រធាន អ.គ.ក Isaac Endeley មិនបានបំពេញការងារដោយសុទ្ធចិត្តឡើយនៅពេលដែលដោះស្រាយបញ្ហានេះ។

18. ដោយផ្អែកលើមូលដ្ឋានទាំងនេះ ភាគីដាក់សំណើ បានស្នើសុំឱ្យ ស.ច.ស ត្រួតពិនិត្យឡើងវិញទៅលើទង្វើរបស់ អ.ប.ក.រ និងប្រធាន អ.គ.ក ហើយបង្គាប់ឱ្យការិយាល័យរដ្ឋបាល ចេញកិច្ចសន្យាការងារជូនលោក Rogers។

## **សាវតារ**

19. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០ លោក Rogers ពេលនោះជាប្រធាន អ.គ.ក បានដាក់លិខិតជូន ស.ច.ស ដោយស្នើសុំលទ្ធភាពចូលពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ និងសិទ្ធិនីតិវិធីផ្សេងទៀតដែលត្រូវបានធានាឱ្យមានតាមរយៈមាត្រា ២១, ៥៥(៨) និង ៥៥(១០)នៃវិធានផ្ទៃក្នុង។ យោងតាមលិខិតដែលបានលើកឡើងខាងលើនេះ លោក Rogers បានពន្យល់

[១១] សំណុំរឿង ០០៤ ឯកសារ D122/2 *ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣ និង៤។

ពីសេចក្តីព្រួយបារម្ភរបស់គាត់ ទាក់ទងនឹងស្ថានភាពរបស់ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយជនសង្ស័យទាំងនោះត្រូវបានបញ្ជាក់ថា *"ត្រូវបានទុកចោលដោយគ្មានតំណាងផ្នែកច្បាប់ក្នុងរូបភាពណាមួយ ឬមធ្យោបាយណាមួយដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយទោះបីជាពួកគេទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីការស៊ើបអង្កេតក៏ដោយ"* [១២]។ បន្ទាប់មក តាមរយៈលិខិតចុះថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ ២០១០ អ.គ.ក បានរំឭកដោយបានផ្តល់ការពន្យល់បន្ថែមទៀត[១៣]។

20. នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ នៅក្នុងលិខិតមួយជូន អ.គ.ក នោះ ស.ច.ស បានពន្យល់ថាតើហេតុអ្វីបានជាសំណើខាងលើទាក់ទងនឹងលទ្ធភាពចូលពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ មិនអាចត្រូវបានអនុញ្ញាត។ ស.ច.ស បានបញ្ជាក់ដូចជា *"សិទ្ធិការពារក្តីអាចអនុវត្តបានយ៉ាងពេញលេញ (ហើយគោលការណ៍សមភាពនៃមធ្យោបាយតទល់រឿងក្តីត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួនទៅពេលដែលជនម្នាក់ត្រូវបានចោទប្រកាន់ ហើយក្លាយជាភាគីនៃកិច្ចដំណើរការនីតិវិធី។ ប៉ុន្តែ ដរាបណាជនណាម្នាក់មិនត្រូវបានចោទប្រកាន់ជាផ្លូវការ សិទ្ធិរបស់ជននោះនៅមានកម្រិតនៅឡើយ។ នេះគឺជាករណីដែលអនុវត្តនៅគ្រប់ប្រព័ន្ធនីតិវិធីទាំងអស់"* [១៤]។

21. បន្ទាប់មក ស.ច.ស បានបញ្ជាក់ពីសេចក្តីសម្រេចខាងលើនេះ៖

ក. នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ស.ច.ស បានចេញ *ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ ០០៣ និង ០០៤* ដោយច្រានចោលញត្តិរបស់មេធាវី

---

[១២] សំណុំរឿង ០០៤ ឯកសារ D4.1.29 *លិខិតរបស់ អ.គ.ក ស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿង ០០៣ និង ០០៤* ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០។

[១៣] សំណុំរឿង ០០៤ ឯកសារ A1/1 *លិខិតរំឭករបស់អង្គភាពគាំពារការពារក្តីស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿង ០០៣ និង ០០៤* ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០។

[១៤] សំណុំរឿង ០០៤ ឯកសារ A1/2 *ចម្លើយតបរបស់ ស.ច.ស ស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ ។

00910686



ដែលត្រូវបានចាត់តាំងបណ្ដោះអាសន្ននៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលស្នើសុំចូលពិនិត្យមើលសំណុំរឿង[១៥]។

ខ. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ ស.ច.ស បានចេញ *ដីកាសម្រេចស្ដីអំពីសំណើពិនិត្យឡើងវិញនូវដីកាសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១* ដែលក្នុងដីកានេះ ស.ច.ស បានច្រានចោលសំណើសុំឱ្យពិចារណាឡើងវិញ ដែលបានដាក់ដោយមេធាវីដែលត្រូវបានចាត់តាំងនៅក្នុងសំណុំរឿង ០០៣ និង ០០៤[១៦]។

22. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ស.ច.ស.អ.ប Laurent Kasper-Ansermet បានចេញសេចក្ដីសម្រេចស្ដីពី*ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* ដែលបានបញ្ជាក់ដូចជាជនសង្ស័យ គឺជា "ជនសង្ស័យដែលមានឈ្មោះ"នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងសំណុំរឿង ០០៤ ហើយបានជូនដំណឹងជនសង្ស័យអំពីខ្លឹមសារនៃបទចោទប្រកាន់ប្រឆាំងនឹងគាត់។ ដូច្នេះ ជនសង្ស័យត្រូវបានជូនដំណឹងថា "*ដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់អ.វ.ត.ក [វិធាន ២១(១)(ឃ)] សិទ្ធិ និងការធានានៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងឋានៈជាជនសង្ស័យ រួមមានសិទ្ធិមានមេធាវីការពារខ្លួនតាមការជ្រើសរើសរបស់ខ្លួន សិទ្ធិមានលទ្ធភាពទទួលបានឯកសារសំណុំរឿង (អនុវត្តស្របគ្នាតាមវិធាន ៥៥(៦) វិធាន ៥៥(១) និងវិធាន ៥៨ លើកលែងតែបញ្ញត្តិនៃវិធាន ៥៨(៦)នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក) និងសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី*"[១៧]។

---

[១៥] សំណុំរឿង ០០៤ ឯកសារ D4/1 *ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ។

[១៦] សំណុំរឿង ០០៤ ឯកសារ D4/2/1 *ដីកាសម្រេចស្ដីអំពីសំណើពិនិត្យឡើងវិញនូវដីកាសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១* ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១។

[១៧] សំណុំរឿង ០០៤ ឯកសារ D110 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១ និង ៤។

23. សេចក្តីសម្រេចនេះ បានបង្កើតឱ្យកាលៈទេសៈពិសេស ដោយបានជូនដំណឹងពីឋានៈជាជនសង្ស័យដល់ជនម្នាក់ដែលគ្រាន់តែមានឈ្មោះនៅក្នុងដីកាសន្និដ្ឋាន[១៨]របស់សហព្រះរាជអាជ្ញា ហើយទាក់ទងនឹងនឹងជននេះ ស.ច.ស មិនបានធ្វើសេចក្តីសម្រេចចោទប្រកាន់នៅពេលណាមួយនោះឡើយ។ បន្ថែមពីលើនេះទៀត សេចក្តីសម្រេចនេះ ភ្ជាប់សិទ្ធិផ្សេងៗជាមួយនឹងឋានៈជាជនសង្ស័យ ហួសពីបទប្បញ្ញត្តិទាក់ទងនឹងសិទ្ធិរបស់ជនសង្ស័យដែលមានចែងនៅក្នុងវិធាន ២១។

24. សេចក្តីសម្រេចស្តីពី *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* ក៏បានស្នើឱ្យ ជនសង្ស័យទាក់ទងអង្គភាពគាំពារការពារក្តី ដើម្បីផ្តល់ជូនជនសង្ស័យ ដូចជា "បញ្ជីឈ្មោះមេធាវីដែលអាចរកបានសម្រាប់ជនគ្រប់រូបដែលមានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់នៅចំពោះមុខ អ.វ.ត.ក [១៩]" ហើយ ស.ច.ស.អ.ប បានជូនដំណឹង អ.គ.ក អំពីសេចក្តីសម្រេចស្តីពី *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ*[២០] ។ នៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១២ អ.គ.ក បានឆ្លើយតបថា ខ្លួនបានទាក់ទងជនសង្ស័យ និងផ្តល់ជូនគាត់នូវបញ្ជីឈ្មោះមេធាវី [២១]។

25. នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ [redacted] មន្ត្រីទទួលបន្ទុក អ.គ.ក បានចាត់តាំងលោក មុំ លុដ្ឋ ជាមេធាវីកម្ពុជាបណ្តោះអាសន្ន ដើម្បីតំណាងជនសង្ស័យ ដោយផ្អែកលើមូលដ្ឋាននៃសំណើ "ទម្រង់ ៧" ដែលទទួលបានពីជនសង្ស័យ។ បន្ថែមពីលើនេះ [redacted] ក៏បានជូនដំណឹង ស.ច.ស ថា ជនសង្ស័យ"*បានជ្រើសរើសមេធាវីបរទេសម្នាក់ គឺលោក Richard Rogers ហើយជាបឋម អ.គ.ក កំពុងស្នើសុំកិច្ចសន្យាប្រឹក្សាផ្នែកច្បាប់សម្រាប់*

---

[១៨] សំណុំរឿង ០០៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។

[១៩] សំណុំរឿង ០០៤ ឯកសារ D110 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៣។

[២០] សំណុំរឿង ០០៤ ឯកសារ D111 ចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៤។

[២១] សំណុំរឿង ០០៤ ឯកសារ D111/1 *លិខិតរបស់អង្គភាពគាំពារការពារក្តីជូន សហចៅក្រមស៊ើបអង្កេត* ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ (១)។

*មេធាវីរូបនេះ ដោយរង់ចាំគាត់ចូលជាសមាជិកនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា"*[២២] ។ ភាគីដាក់សំណើ បញ្ជាក់ថា ដោយអនុវត្តតាមបទដ្ឋានរបស់ អ.គ.ក លោក Rogers ត្រូវបានបញ្ចូលទៅក្នុងបញ្ជីមេធាវីដែលមន្ត្រីទទួលបន្ទុក អ.គ.ក បានផ្តល់ជូនទៅជនសង្ស័យ ដោយផ្អែកលើមូលដ្ឋានថា គាត់បានបំពេញតាមលក្ខណវិនិច្ឆ័យពាក់ព័ន្ធ ទោះបីជាពេលនោះមិនទាន់ចុះបញ្ជីនៅគណៈមេធាវីកម្ពុជា ក៏ដោយ[២៣]។

26. នៅថ្ងៃទី [redacted] មន្ត្រីទទួលបន្ទុក អ.គ.ក បានចាកចេញពីការងារនៅ អ.វ.ត.ក។

27. នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១២ លោក មុំ លុជ្ស និង លោក Rogers បានសរសេរលិខិតជូន ស.ច.ស ដោយបញ្ជាក់ថា ពួកគាត់ទទួលបានការណែនាំពីជនសង្ស័យ ទាក់ទងនឹងសេចក្តីសម្រេចរបស់ជនសង្ស័យក្នុងការអនុវត្តសិទ្ធិនៅស្ងៀម និងដោយស្នើឱ្យមាន "សិទ្ធិ និងបុព្វសិទ្ធិទាំងអស់ដែលផ្តល់ឱ្យក្រុមមេធាវីការពារក្តីទាំងអស់នៅ អ.វ.ត.ក រួមទាំងសិទ្ធិចូលមើលសំណុំរឿង..."[២៤]។

28. នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ លោក Isaac Endeley បានចូលកាន់តំណែងជាប្រធាន អ.គ.ក។

29. នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ លោក Isaac Endeley បានដកសំណើមុនដែលស្នើសុំសេវាប្រឹក្សាច្បាប់សម្រាប់លោក Rogers ដោយផ្អែកលើមូលដ្ឋាននៃ "i)*លទ្ធភាពទំនាស់ផលប្រយោជន៍បណ្តាលមកពីតួនាទីពីមុនរបស់លោក Rogers ជាប្រធាន អ.គ.ក ii) ការយល់ឃើញអំពីភាពមិនប្រក្រតីខាងនីតិវិធីនៅក្នុងដំណើរការចាត់តាំង និង iii) អង្គហេតុដែលថា លោក Rogers មិនទាន់ត្រូវបានចូលជាសមាជិកនៅគណៈមេធាវីនៃព្រះរាណាចក្រកម្ពុជា ដូច្នេះ*

---

[២២] សំណុំរឿង ០០៤ ឯកសារ D111/2 *ការចាត់តាំងលោក មុំ លុជ្ស ជាមេធាវីជាតិបណ្តោះអាសន្នសម្រាប់ជនសង្ស័យឈ្មោះ*[redacted]*នៅក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៧ និង ៨ ។

[២៣] សំណុំរឿង ០០៤ ឯកសារ D122/2 *ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* កថាខណ្ឌ ១០-១២ ។

[២៤] សំណុំរឿង ០០៤ ឯកសារ D111/3 *លិខិតរបស់ក្រុមមេធាវីការពារក្តី ជូន ស.ច.ស* ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ២០១២ ។

*ហើយទើបគាត់មិនមានសិទ្ធិ ឬគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីតំណាងជនក្រីក្រនៅចំពោះមុខ អ.វ.ត.ក ឡើយ"* [២៥]។

30. នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២ អ.គ.ក បានជូនដំណឹង ស.ច.ស ថា ជនសង្ស័យមិនមានមធ្យោបាយគ្រប់គ្រាន់ដើម្បីបង់ថ្លៃមេធាវីការពារក្តីរបស់ខ្លួន ហើយបានស្នើសុំឱ្យ ស.ច.ស "កត់សម្គាល់លើការចាត់តាំងលោក មុំ លុជ្ស ជាមេធាវីជាតិអចិន្ត្រៃយ៍"សម្រាប់ជនសង្ស័យ ព្រមទាំងបានកត់សម្គាល់ថា *"ដំណើរការចាត់តាំងមេធាវីបរទេស...កំពុងបន្តដំណើរការ"* [២៦]។

31. នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២ នេះដែរ ស.ច.ស.អ.ប Kasper-Ansermet បានចេញ*ដីកាសម្រេចទទួលស្គាល់* ដោយបញ្ជាក់ថា *"លោក មុំ លុជ្ស និង លោក Richard Rogers ត្រូវបានជនសង្ស័យជ្រើសរើស និងជួលជាមេធាវី យ៉ាងត្រឹមត្រូវ ដោយអនុលោមតាមសិទ្ធិរបស់គាត់ក្នុងការទទួលបានមេធាវីតាមជម្រើសរបស់ខ្លួន"* [២៧]។ ដោយកត់សម្គាល់ថា រដ្ឋបាលរបស់ UNAKRT "មិនបានចេញកិច្ចសន្យាការងារជូន លោក Roggers ឬមិនបានផ្តល់មូលហេតុជូនសហចៅក្រមស៊ើបអង្កេត អំពីការដែលមិនបានធ្វើដូច្នេះ ស.ច.ស.អ.ប បានបង្គាប់ឱ្យការិយាល័យរដ្ឋបាល រួមទាំង អ.គ.ក *"ទទួលស្គាល់ការចាត់តាំងលោក មុំ លុជ្ស និងលោក Rogers លុះត្រាតែ ការតំណាងជាមេធាវីរបស់ពួកគាត់ត្រូវដកចេញដោយ [ជនសង្ស័យ] ឬ ដោយអង្គជំនុំជម្រះ/សមត្ថកិច្ចតុលាការសមស្រប"*។

32. នៅថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១២ ស.ច.ស.អ.ប Kasper-Ansermet បានបញ្ចប់ការងាររបស់គាត់ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅ អ.វ.ត.ក។

---

[២៥] សូមមើលសំណុំរឿង ០០៤ ឯកសារ D111/6 *អនុស្សរណៈរបស់ការិយាល័យរដ្ឋបាលជូនចំពោះ ស.ច.ស ការបញ្ជាក់ទាក់ទងនឹង "ដីកាសម្រេចទទួលស្គាល់មេធាវី"* ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ១៧ និងឧបសម្ព័ន្ធ XII (ឯកសារ D111/6.12) ។

[២៦] សំណុំរឿង ០០៤ ឯកសារ D111/4 *លិខិតរបស់អង្គភាពគាំពារការពារក្តី* ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២។

[២៧] សំណុំរឿង ០០៤ ឯកសារ D111/5 *ដីកាសម្រេចទទួលស្គាល់មេធាវី*ដំណោះស្រាយ។

33. ភាគីដាក់សំណើ កត់សម្គាល់ថា លោក Rogers បានស្បថចូលកាន់តំណែង នៅសាលាឧទ្ធរណ៍របស់ប្រទេសកម្ពុជា នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៣[២៨]។

34. នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១២ អ.ប.ក.វ Khnut Rosandhaug បានដាក់អនុស្សរណៈមួយចំណងជើង *ការបញ្ជាក់ទាក់ទងនឹង "ដីកាសម្រេចទទួលស្គាល់មេធាវី"* ("អនុស្សរណៈ") ជូន ស.ច.ស ដោយកត់សម្គាល់ថា មានភាពមិនច្បាស់លាស់មួយចំនួនទាក់ទងនឹងថាតើលោក Rogers ត្រូវបានជួលជាមេធាវី ឬគ្រាន់តែជាទីប្រឹក្សាផ្នែកច្បាប់ ហើយដោយបញ្ជាក់ទៀតថា "*នៅត្រឹមកាលបរិច្ឆេទនៃ "ដីកាសម្រេចទទួលស្គាល់មេធាវី" លោក Rogers នៅមិនទាន់បំពេញតាមលក្ខណវិនិច្ឆ័យ ហើយមិនត្រូវបានបញ្ចូលទៅក្នុងបញ្ជីមេធាវី ដូច្នេះទើបមិនមានសិទ្ធិតំណាងជនសង្ស័យ ឬជនជាប់ចោទណាម្នាក់នៅចំពោះមុខ អ.វ.ត.ក ឡើយ។ នៅមិនច្បាស់អំពីរបៀបដែល[ជនសង្ស័យ]បានមកស្គាល់លោក Rogers ឬមូលហេតុដែលការព្រមព្រៀងការងាររវាងពួកគាត់នឹងត្រូវចាត់ទុកថាស្ថិតនៅក្រោមគម្រោងជំនួយផ្នែកច្បាប់ឡើយ*"[២៩]។

35. នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាអន្តរជាតិ Andrew Cayley បានផ្ញើជូន អ.ប.ក.វ នូវសារអេឡិចត្រូនិកមួយជម្រាបអំពីសេចក្តីព្រួយបារម្ភរបស់គាត់ដែលថាគោលការណ៍ស្តីពីភាពយុត្តិធម៌ និងសិទ្ធិទទួលបានការដឹងឮ តម្រូវឱ្យជូនដំណឹងលោក Rogers អំពីអនុស្សរណៈនោះ ។

36. នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២ អ.ប.ក.វ បានដាក់អនុស្សរណៈបន្ថែមមួយទៀត ចំណងជើង *ការបញ្ជាក់ទាក់ទងនឹង "ដីកាសម្រេចទទួលស្គាល់មេធាវី" សេចក្តីបារម្ភរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ជូន ស.ច.ស ដោយចម្លងជូនសារអេឡិចត្រូនិកខាងលើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[៣០]។

---

[២៨] សំណុំរឿង ០០៤ ឯកសារ D122/2 *ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យ* កថាខណ្ឌ១៨ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ។

[២៩] សំណុំរឿង ០០៤ ឯកសារ D111/6 *អនុស្សរណៈរបស់ការិយាល័យរដ្ឋបាលជូន ស.ច.ស ការបញ្ជាក់ទាក់ទងនឹង"ដីកាសម្រេចទទួលស្គាល់មេធាវី"* ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១២។

[៣០] សំណុំរឿង ០០៤ ឯកសារ D111/7 *អនុស្សរណៈរបស់ការិយាល័យរដ្ឋបាលជូន ស.ច.ស ការបញ្ជាក់ទាក់ទងនឹង"ដីកាសម្រេចទទួលស្គាល់មេធាវី" សេចក្តីព្រួយបារម្ភរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២។

37. នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ ប្រធាន អ.គ.ក បានជូនដំណឹង លោក Rogers ថា ប្រធាន អ.គ.ក បានបដិសេធមិនដាក់ឈ្មោះគាត់ចូលទៅក្នុងបញ្ជីសហមេធាវីបរទេសដែលអាចមានសិទ្ធិនោះ គឺផ្អែកលើមូលដ្ឋានថា គាត់ខ្វះបទពិសោធន៍ការងារដែលតម្រូវឱ្យមាននៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និងសេចក្តីប្រារព្ធរបស់ប្រធាន អ.គ.ក អំពីទំនាស់ផលប្រយោជន៍ និងទំនាស់វិជ្ជាជីវៈដែលមានជាក់ស្តែង ឬដែលអាចកើតឡើង[៣១]។

38. នៅថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១២ បន្ទាប់ពីបានជូនដំណឹងដល់ជនសង្ស័យនៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១២ ថា លោក Rogers នឹងមិនត្រូវចាត់តាំងតំណាងគាត់ទេ[៣២] ប្រធាន អ.គ.ក បានជូនដំណឹង ស.ច.ស ថា ជនសង្ស័យ បានជ្រើសរើសលោក Goran Sluiter ជាសហមេធាវីបរទេសរបស់គាត់ ហើយ ដោយបានស្បថចូលកាន់តំណែងនៅសាលាឧទ្ធរណ៍របស់ប្រទេសកម្ពុជានៅកាលបរិច្ឆេទ នោះ លោក Goran Sluiter ត្រូវបានចាត់តាំងជាសហមេធាវីបរទេសតំណាងជនសង្ស័យនៅចំពោះមុខ អ.វ.ត.ក នៅក្នុងសំណុំរឿង ០០៤[៣៣]។

39. នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ លោក មុំ លុជ្ស បានធ្វើលិខិតមួយជូន ស.ច.ស ដោយធ្វើការណែនាំឱ្យស្គាល់ក្រុមមេធាវីការពារក្តីរបស់ជនសង្ស័យ ដោយបានអះអាងថា ជនសង្ស័យត្រូវបានតំណាងដោយលោក Goran Sluiter និង លោក Rogers ផងដែរ ។ លោក មុំ លុជ្ស ក៏បានធ្វើសំណើដូចជា ស្នើសុំឱ្យ“*សហចៅក្រមស៊ើបអង្កេត ធានាថា ជនសង្ស័យនៅចំពោះមុខ អ.វ.ត.ក ទទួលបានសិទ្ធិទាំងអស់របស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះក្តីប្រកប*

---

[៣១] សំណុំរឿង ០០៤ ឯកសារ D122/2.1.50 *លិខិតពីប្រធាន អ.គ.ក ជូនលោក Rogers* ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ១៤៖ *ខណៈដែលកង្វះបទពិសោធន៍ជាប់ពាក់ព័ន្ធដូចបានបញ្ជាក់ខាងលើ រារាំងមិនឱ្យលោក ត្រូវបានបញ្ចូលទៅក្នុងបញ្ជីមេធាវីនោះ ក៏នៅមានបញ្ហាមួយចំនួនទៀតទាក់ទងនឹងទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬអាចកើតឡើងដែលមានឥទ្ធិពលមិនអាចតែងតាំងលោក ជាសហមេធាវី*”។

[៣២] សូមមើលសំណុំរឿង ០០៤ ឯកសារ D111/6 *អនុស្សរណៈរបស់ការិយាល័យរដ្ឋបាលជូន ស.ច.ស ការបញ្ជាក់ទាក់ទងនឹង “ដីកាសម្រេចទទួលស្គាល់មេធាវី”* ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ២១ និងឧបសម្ព័ន្ធ XIV (ឯកសារ D111/6.12) ។

[៣៣] សំណុំរឿង ០០៤ ឯកសារ D111/8 *លិខិតរបស់ អ.គ.ក ការចាត់តាំងមេធាវីអន្តរជាតិ* ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១២។

*ដោយយុត្តិធម៌ ហើយសិទ្ធិទាំងនេះមិនត្រូវតែទ្រឹស្ដី និងបំភ័ន្តឡើយ ប៉ុន្តែត្រូវមានពិតប្រាកដ និងប្រកបដោយប្រសិទ្ធភាព*"[៣៤]។

40. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ ភាគីដាក់សំណើ បានដាក់*សំណើជាបន្ទាន់សុំ ដីកាអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង* ក្នុងនាមជា "ជនត្រូវចោទ" ដោយរំឭកថា "*ជនត្រូវចោទត្រូវបានជូនដំណឹងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងថា គាត់មានសិទ្ធិចូលទៅពិនិត្យសំណុំរឿង*"[៣៥]។

41. នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២ ភាគីដាក់សំណើ បានផ្ញើលិខិតមួយពាក់ព័ន្ធនឹង*សិទ្ធិ*[redacted] *ក្នុងការទទួលបានព័ត៌មានស្ដីពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើរូបគាត់ និងសិទ្ធិក្នុងការទទួលបានសម្ភារៈរូបវ័ន្តគ្រប់គ្រាន់សម្រាប់ត្រៀមរៀបចំការពារក្ដីរបស់ខ្លួន* ដោយកត់សម្គាល់ថា ជនរងគ្រោះ ត្រូវបានជូនដំណឹងអំពីវិសាលភាពនៃការស៊ើបអង្កេត ហើយ "បែរជាមិនមានការខិតខំ ឬមានការខិតខំបន្តិចបន្តួចក្នុងការជូនដំណឹងគាត់អំពីខ្លឹមសារនៃការចោទប្រកាន់ និងលក្ខណៈនៃការវិវិត្តនៅក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងលើរូបគាត់"[៣៦]។

42. នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣ ភាគីដាក់សំណើ បានដាក់*សំណើបន្ទាន់សុំបន្ថែមចំនួនទំព័រសម្រាប់សំណើស្ដីពីសិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានមេធាវី* ហើយសំណើបន្ទាន់នេះត្រូវបានអនុញ្ញាតនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣[៣៧] បន្ទាន់ពីមានការចុះហត្ថលេខាលើកំណត់ហេតុនៃករណីខ្វែងយោបល់គ្នារវាង ស.ច.ស នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣។ *ញត្តិស្ដីពី*

---

[៣៤] សំណុំរឿង ០០៤ ឯកសារ D122/2.1.41 *លិខិតរបស់ អ.ត.ក ជូន ស.ច.ស* ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១២ ។

[៣៥] សំណុំរឿង ០០៤ ឯកសារ D121 *សំណើជាបន្ទាន់សុំ ដីកាអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង* ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៣។

[៣៦] សំណុំរឿង០០៤ ឯកសារ D121/1 *សិទ្ធិតា អាន ក្នុងការទទួលបានព័ត៌មានស្ដីពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើរូបគាត់ និងសិទ្ធិក្នុងការទទួលបានសម្ភារៈរូបវ័ន្តគ្រប់គ្រាន់សម្រាប់ត្រៀមរៀបចំការពារក្ដីរបស់ខ្លួន* ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១២ ។

[៣៧] សំណុំរឿង ០០៤ ឯកសារ D122/1 *សេចក្ដីសម្រេចលើសំណើបន្ទាន់សុំបន្ថែមចំនួនទំព័រសម្រាប់ញត្តិស្ដីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣។

*សិទ្ធិរបស់ជនសង្ស័យ* ត្រូវបានដាក់ចូលដោយភាគីដាក់សំណើនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣។

43. នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៣ ភាគីដាក់សំណើបានដាក់ការជូនដំណឹងស្តីពីបំណងថានឹងផ្ញើជូនសារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី ហើយនៅថ្ងៃទី១២ ខែ មេសា ឆ្នាំ ២០១២ *សារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី*ត្រូវបានដាក់ចូល។

## សំអាងហេតុសម្រាប់សេចក្តីសម្រេចនេះ

### អំណាចពិចារណាឡើងវិញទៅលើសេចក្តីសម្រេចមុនៗរបស់ ស.ច.ស

44. ស.ច.ស កត់សម្គាល់ទៅលើអំណាចមានស្រាប់របស់ចៅក្រម[38] រួមទាំង ចៅក្រមអ.វ.ត.ក[39] ផងដែរ ក្នុងការពិចារណាឡើងវិញទៅលើសេចក្តីសម្រេចមុនណាមួយក្នុងករណីដែលមានការប្រែប្រួលកាលៈទេសៈ (អង្គហេតុថ្មី ទឡ្ហីករណ៍ថ្មី) និងក្នុងករណីដែលសេចក្តីសម្រេចមុនមានកំហុសឆ្គង ឬអាចបណ្តាលឲ្យមានភាពអយុត្តិធម៌[40]។

---

[38] តុលាការ ICTY ព្រះរាជអាជ្ញា តទល់នឹង Galic, IT-98-29-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ *សេចក្តីសម្រេចលើ សំណើរបស់ក្រុមមេធាវីការពារក្តីសុំឱ្យពិចារណាឡើងវិញ* ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ២។ តុលាការICTY, *Milosevic* តទល់នឹងរដ្ឋអាជ្ញា, IT-02-54-AR73.7, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការតែងតាំងមេធាវីការពារក្តី* ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ កថាខណ្ឌ ៩-១០។ ការដកស្រង់នៅក្នុងសំណុំរឿងលេខ 002/19-09-2007-ECCC/PTC-D164/4/13 របស់ អ.វ.ត.ក *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម* ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ២៦។

[39] ក្នុងករណីដែលវិធានផ្ទៃក្នុង និងច្បាប់កម្ពុជា ពុំបានចែងពីបញ្ញាពិសេសណាមួយ គេអាចស្វែងរកការណែនាំនៅក្នុងការអនុវត្តអន្តរជាតិ[មាត្រា ១២(១)នៃកិច្ចព្រមព្រៀងអ.វ.ត.ក និង មាត្រា ២៣ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក]។ អង្គបុរេជំនុំជម្រះបានធ្វើការពិចារណាឡើងវិញរួចហើយទៅលើសេចក្តីសម្រេចមុនៗ៖ ឯកសារ ECCC CF002/19-09-2007-ECCC/PTC-C22/1/68 *សេចក្តីសម្រេចលើពាក្យសុំពិចារណាសាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង* ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ ២៥ និងឯកសារ ECCC CF002/19-09-2007- ECCC/PTC-D364/1/6 *សាលដីកាសម្រេចអំពីការពិចារណាសាជាថ្មីឡើងវិញអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ៩។

[40] តុលាការ ICTY *រដ្ឋអាជ្ញាតទល់នឹង Milosevic*, IT-02-54-T អង្គជំនុំជម្រះសាលដំបូង *សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឱ្យធ្វើការពិចារណាឡើងវិញទាក់ទងនឹងភស្តុតាងរបស់សាក្សីការពារក្តីឈ្មោះ Mitar Balevic, Vladislav*

## មូលដ្ឋានសម្រាប់ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី

## ក) ច្បាប់ជាធរមាន

45. បញ្ហាដែលកើតឡើងនៅក្នុងករណីបច្ចុប្បន្ននេះគឺនៅត្រង់ចំណុចថា នៅក្នុងការស៊ើបអង្កេត ប្រសិនបើមាន សិទ្ធិរបស់ជនសង្ស័យដូចមានចែងនៅក្នុងវិធាន ២១(ឃ) គឺជាសិទ្ធិរបស់ជនពិសេសម្នាក់។ មូលដ្ឋាននៃញត្តិស្តីពីសិទ្ធិក្នុងការមានមេធាវី គឺជាសញ្ញាណដែលថា ជនសង្ស័យមានសិទ្ធិទទួលបានតំណាងផ្នែកច្បាប់នៅក្នុងសំណុំរឿង ០០៤ ទោះបីជាមិនត្រូវបានចោទប្រកាន់ជាផ្លូវការពី ស.ច.ស ក៏ដោយ។

46. ទាំង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង វិធានផ្ទៃក្នុង មានបទប្បញ្ញត្តិទាក់ទងនឹងសិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានមេធាវី។ មាត្រា ២៤ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺជាការបញ្ជាក់ទូទៅទាក់ទងនឹងបទដ្ឋានអន្តរជាតិ ហើយចែងថា "ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវី ដែលជ្រើសរើសដោយខ្លួនឯងដោយខានមិនបាន និងមានជំនួយផ្នែកច្បាប់ដល់ពួកគេដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីពឹងមេធាវី ព្រមទាំងមានសិទ្ធិទទួលបាននូវការបកប្រែចាំបាច់ជាភាសាដែលជនសង្ស័យនិយាយ និងយល់បាន[41] "។

---

*Jovanovic, Vukasin Andric* *និង* *Dobre Aleksovski* *និងសេចក្តីសម្រេច* *proprio motu* *ពិចារណាឡើងវិញលើការទទួលយកវត្ថុតាង 837 និង 838 ទាក់ទងនឹងភស្តុតាងរបស់សាក្សីការពារក្តីឈ្មោះ* Barry Lituch ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ៧-៨។ តុលាការ ICTY រដ្ឋអាជ្ញា តទល់នឹង *Galic*, IT-98-29-AR73 អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ *សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំការអនុញ្ញាតប្តឹងឧទ្ធរណ៍* ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០១ កថាខណ្ឌ ១៣។ តុលាការ ICTY *រដ្ឋអាជ្ញាតទល់នឹង Mucic និងអ្នកផ្សេងទៀត* IT-96-21-A*bis*, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ *សាលដីកាលើបណ្តឹងឧទ្ធរណ៍អំពីការកាត់ទោស* ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០០៣។ តុលាការ ICTY *រដ្ឋអាជ្ញាតទល់នឹង* *Milutinovic* និងអ្នកផ្សេងទៀត IT-05-87-T អង្គជំនុំជម្រះសាលាដំបូង *សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឱ្យពិចារណាឡើងវិញ ទៅលើសេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឱ្យមានវិធានការការពារបន្ថែមទាក់ទងនឹងការជំនុំជម្រះសម្រាប់សាក្សី K56* ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ២។

[41] ទោះបីយ៉ាងណា អ.វ.ត.ក មិនមាននិយមន័យពាក់ព័ន្ធនឹងពាក្យ"ជនសង្ស័យ"នៅក្នុងបរិបទនៃសេចក្តីសម្រេចនេះឡើយ។

47. សន្ទានុក្រមនៃវិធានផ្ទៃក្នុង បញ្ជាក់ថា "ជនសង្ស័យ" គឺជា"*បុគ្គលដែលសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត ចាត់ទុកថាអាចធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែមិនទាន់ត្រូវបានចោទប្រកាន់នៅឡើយ*" ចំណែកឯ "ជនត្រូវចោទ" សំដៅលើ "*បុគ្គលណាម្នាក់ដែលត្រូវបានចោទប្រកាន់ចំពោះរឿងក្តីណាមួយក្នុងចន្លោះពេលពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ រហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់*"។

48. វិធានផ្ទៃក្នុង ២១(ឃ) ចែងអំពីសិទ្ធិដែលជនសង្ស័យមានសិទ្ធិទទួលបាន។ វិធាននេះចែងថា "*ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប*"។

49. មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាល ឆ្នាំ ១៩៦៦ ដែលអាចអនុវត្តផ្ទាល់នៅចំពោះមុខ អ.វ.ត.ក យោងតាមមាត្រា ១២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក[42] ចែងអំពីផ្នែកជាប់ពាក់ព័ន្ធថា ៖

> *៣.ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញដូចខាងក្រោម៖*
>
> *[...]*
>
> *(ឃ)ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ត្រូវទទួលបានជំនួយការច្បាប់សម្រាប់*

---

[42] កិច្ចព្រៀមព្រៀង អ.វ.ត.ក មាត្រា ១២ កថាខណ្ឌ ១ (...) "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ"។

*ខ្លួនក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។*

## ខ) សេចក្តីសម្រេចមុនៗរបស់ ស.ច.ស ទាក់ទងនឹងសិទ្ធិរបស់ជនសង្ស័យ

50. នៅក្នុងការទទួលស្គាល់សិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានការការពារពីមេធាវីតាមជម្រើសរបស់ខ្លួន សេចក្តីសម្រេចស្តីពី*ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* បានលុបចោលសេចក្តីសម្រេចមុនៗជាបន្តបន្ទាប់របស់ ស.ច.ស ដែលបដិសេធមិនព្រមផ្តល់សិទ្ធិក្នុងការទទួលបានមេធាវីដល់ជនដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[៤៣] ដោយមិន

---

[៤៣] សំណុំរឿង ០០៤ ឯកសារ A1/2 *ចម្លើយតបរបស់ ស.ច.ស ស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ៣៖ *"សិទ្ធិការពារក្តីអាចអនុវត្តបានយ៉ាងពេញលេញ (ហើយគោលការណ៍សមភាពនៃមធ្យោបាយតទល់រឿងក្តីត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួននៅពេលដែលជនម្នាក់ត្រូវបានចោទប្រកាន់ ហើយក្លាយជាភាគីនៃកិច្ចដំណើរការនីតិវិធី។ ប៉ុន្តែ ដរាបណាជនណាម្នាក់មិនត្រូវបានចោទប្រកាន់ជាផ្លូវការ សិទ្ធិ របស់ជននោះនៅមានកម្រិតនៅឡើយ។ នេះគឺជាករណីដែលអនុវត្តនៅគ្រប់ប្រព័ន្ធនីតិវិធីទាំងអស់"* ។ កថាខណ្ឌ ៤៖ *នៅក្នុងករណីនេះ វិធានផ្តែផ្តួងបញ្ជាក់អំពីសិទ្ធិនានារបស់ជនសង្ស័យ ដូចជា នៅក្នុងករណីនៃការស្តាប់ចម្លើយ (វិធាន ២៤-៤ និងវិធាន ២៨ ការឃាត់ខ្លួន (វិធាន ៥១) ឬក្នុងករណីនៃការឆែកឆេរ (វិធាន ៦១)។ ប្រសិនបើមានស្ថានភាពណាមួយក្នុងចំណោមស្ថានភាពទាំងនេះកើតមានឡើង "ជនសង្ស័យមិនស្គាល់ឈ្មោះ"ដែលលោកបានលើកឡើងនឹងទទួលបានយ៉ាងពេញលេញនូវសិទ្ធិសម្រាប់ស្ថានភាពបែបនោះ។ ប៉ុន្តែ ជនទាំងនោះនៅតែមិនអាចទាមទារនូវសិទ្ធិដែលដូចគ្នាទៅនឹងភាគីនៃដំណើរការនីតិវិធីឡើយ ដូចជាសិទ្ធិដែលមានចែងនៅក្នុងវិធាន ៥៥(៨) វិធាន ៥៥(១០) វិធាន៥៥(១១) វិធាន ៥៧ និង វិធាន ៥៨ ជាដើម ដោយហេតុថា មិនមានអ្នកណាម្នាក់អាចធ្វើបុរេវិនិច្ឆ័យអំពីចំណាត់ការបន្តចំពោះការស៊ើបសួរដែលកំពុងតែដំណើរការនោះឡើយ"*។

សំណុំរឿង ០០៤ ឯកសារ D4/1 *ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ [ត្រូវបានបញ្ជាក់នៅពេលប្តឹងឧទ្ធរណ៍៖ សំណុំរឿង ០០៤/២៩-០៧-២០១១-អ.វ.ត.ក/(អ.ប.ជ 01) *សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងស្នើសុំវិធានការទាក់ទងនឹងការតំណាងជនសង្ស័យប្រកបដោយប្រសិទ្ធភាពនៅក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២]៖ *"លោក គង់ សំអុន មិនមានសិទ្ធិក្នុងការតំណាងជនសង្ស័យដែលមិនទាន់កំណត់ឈ្មោះឡើយ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធី"*

បានផ្តល់សំអាងណាក្រៅពីការលើកឡើងវិធានផ្ទៃក្នុង ២១ ហើយក៏មិនបានផ្តល់ការបកស្រាយទូលំទូលាយទៅលើបទប្បញ្ញត្តិនេះដែរ។ ដូច្នេះ ស.ច.ស មានសិទ្ធិអំណាចពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចទាំងនេះ ដែលហាក់ដូចជាមានបញ្ហា ដើម្បីសម្រេចលើគោលការណ៍ដែលអាចអនុវត្តបាន។

51. បទប្បញ្ញត្តិនៃវិធានផ្ទៃក្នុងទាក់ទងនឹងសិទ្ធិរបស់ជនត្រូវចោទ[៤៤] ដែលឆ្លុះបញ្ចាំងពីក្រមនីតិព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ត្រង់ចំណុចនេះ[៤៥] គឺលើកឡើងបញ្ហាអនុវត្តតាមបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិរបស់ជនសង្ស័យមុនពេលត្រូវចោទ។

---

(កថាខណ្ឌ ២)។ "*នៅក្នុងដំណាក់កាលនេះនៃការស៊ើបសួរ ជនសង្ស័យដែលមិនទាន់កំណត់ឈ្មោះ មិនទាន់បានទទួលព័ត៌មានផ្លូវការពីដំណើរការនីតិវិធីព្រហ្មទណ្ឌទេ ហើយក៏មិនទាន់រងការប៉ះពាល់ជាក់លាក់ណាមួយដែលដល់កម្រិតច្បាប់តម្រូវឱ្យមានសិទ្ធិតែងតាំងមេធាវីដើម្បីការពារផលប្រយោជន៍អ្នកទាំងនោះនៅឡើយដែរ*" (កថាខណ្ឌ ៣)។ "*មិនទាន់មានជនសង្ស័យណាម្នាក់ក្នុងចំណោមជនសង្ស័យដែលមិនទាន់កំណត់ឈ្មោះទាំងនោះ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរអ្នកទាំងនោះ ត្រូវបានគេទាក់ទង សួរយកចម្លើយ ក្លាយជាកម្មវត្ថុនៃការឆែកឆេរ និងការរឹបអូស ឃុំខ្លួន ឬត្រូវទទួលរងការប៉ះពាល់តាមវិធីដទៃទៀត ដោយការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតទេ នោះមិនទាន់និយាយដល់លក្ខណៈដែលគេអាចនិយាយបានថាជាកម្រិតនៃការប៉ះពាល់ជាក់លាក់ដល់ពួកគេទាំងនោះនៅឡើយទេ*" (កថាខណ្ឌ ៨)។ "*ផលប្រយោជន៍របស់ជនសង្ស័យទាំងប្រាំរូបដែលមិនទាន់កំណត់ឈ្មោះ មិនត្រូវបានប៉ះពាល់ជាក់លាក់ដោយសារការស៊ើបសួរ*" (កថាខណ្ឌ ១១)។

សំណុំរឿង ០០៤ ឯកសារ D4/2/1 *ដីកាសម្រេចស្តីអំពីសំណើពិនិត្យឡើងវិញនូវដីកាសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១* ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ (កថាខណ្ឌ ៥)៖ "*មេធាវីការពារក្តីថែមទាំងបានធ្វើការសន្មតប៉ាន់ស្មានទាក់ទងនឹងអត្តសញ្ញាណរបស់ជនសង្ស័យមិនបង្ហាញអត្តសញ្ញាណនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ប៉ុន្តែផ្ទុយទៅវិញ បែរជាព្យាយាមលើកឡើងថា ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានបណ្តាលឱ្យមានព្យសនកម្មចំពោះជនសង្ស័យទាំងនេះទៅវិញ ។ ទោះបីយ៉ាងណាក្តី ចំពោះការណ៍ដែលមេធាវីការពារក្តីបានលើកឡើងអំពីជនសង្ស័យដែលខ្លួនពុំបានស្គាល់ផងនោះថាបានទទួលរងព្យសនកម្ម គឺជាការអះអាងមួយដែលមានសភាពឥតន័យយ៉ាងជាក់ស្តែង*" និង សំណុំរឿង ០០៤/២៩-០៧-២០១១-អ.វ.ត.ក/(អ.ប.ជ 01) *សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើរបស់អង្គភាពគាំពារការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងស្នើសុំវិធានការទាក់ទងនឹងការតំណាងជនសង្ស័យប្រកបដោយប្រសិទ្ធភាពនៅក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១០-១២។

[៤៤] មាត្រា ២១, ៥៥, ៥៧ និង ៥៨ នៃវិធានផ្ទៃក្នុង ។

52. ករណីយុត្តិសាស្ត្ររបស់ ក.ស.ច.ស ដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ២០ និង ២១ ខាងលើ ដោយដាក់កម្រិតលើសិទ្ធិការពារក្តី គឺផ្អែកលើមូលដ្ឋានជាសំខាន់ទៅលើការយល់ឃើញថា ជនសង្ស័យ មិនអាចត្រូវចាត់ទុកជា "ជនត្រូវចោទ" ដែលមានន័យថាជាសិទ្ធិការពារក្តីពេញលេញ រហូតទាល់តែ ស.ច.ស បាននាំជននោះមកនៅចំពោះមុខខ្លួន ហើយបានជូនដំណឹងជាផ្លូវការដល់គាត់ ក្រោមវិធានផ្ទៃក្នុង ៥៥(៤) និង ៥៧ ថា មានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាបង្ហាញថា គាត់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានរបស់ការិយាល័យសហព្រះរាជអាជ្ញា ទោះបីជាថាជននោះជាប់ ឬមិនជាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋាននោះក៏ដោយ[៤៦]។

---

[៤៥]វិធានផ្ទៃក្នុង ២១៖ "(...) ឃ) *ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើស ដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប*" ។ វិធានផ្ទៃក្នុង ៥៧៖ "*១.នៅពេលជនត្រូវចោទចូលបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និងប្រាប់ជននោះអំពីបទចោទប្រកាន់ និងអំពីសិទ្ធិមានមេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប។ ជនត្រូវចោទមានសិទ្ធិពិគ្រោះជាមួយមេធាវីមុនពេលដែលខ្លួនត្រូវបានសួរចម្លើយ និងមានមេធាវីអមជាមួយនៅក្នុងពេលសួរចម្លើយ។ ប្រសិនបើជនត្រូវចោទយល់ព្រមឆ្លើយ នោះសហចៅក្រមស៊ើបអង្កេត ត្រូវការសួរចម្លើយនោះភ្លាម។ កំណត់ហេតុសួរចម្លើយត្រូវដាក់ចូលក្នុងសំណុំរឿង។ ២. នៅពេលដែលជនត្រូវចោទត្រូវបានឃុំខ្លួន ជននោះត្រូវមានសិទ្ធិលើកឡើងបញ្ហាពាក់ព័ន្ធទៅនឹងការអនុវត្តបទប្បញ្ញត្តិ ឬនីតិវិធីឲ្យបានត្រឹមត្រូវពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន*"។

[៤៦]សំណុំរឿង ០០៤ ឯកសារ A1/2 *ចម្លើយតបរបស់ ស.ច.ស ស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០។ សំណុំរឿង ០០៤ ឯកសារ D4/1 *ដីកាសម្រេចលើសំណើសុំមើលសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១។ សំណុំរឿង ០០៤ ឯកសារ D4/2/1 *ដីកាសម្រេចស្តីអំពីសំណើពិនិត្យឡើងវិញនូវដីកាសម្រេចលើសំណើរបស់មេធាវី ការពារក្តីសុំពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១* ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១។ សម្រាប់ការដកស្រង់ផ្សេងៗពីសេចក្តីសម្រេចទាំងនេះ សូមមើលចុងទំព័រ ៤៣ ខាងលើ។

53. ពិតណាស់ សិទ្ធិជាសារវ័ន្តក្នុងការទទួលបានមេធាវី ក្រោមវិធាន ១៤ នៃICCPR ដូចបានបកស្រាយដោយយោបល់រួមរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ៣២[47] គឺកំណត់ត្រឹមជនដែលត្រូវបានចោទប្រកាន់ព្រហ្មទណ្ឌ[48]។ បទប្បញ្ញត្តិនៃមាត្រា ៦ នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប (ECHR)គឺមានន័យដូចគ្នានឹងបទប្បញ្ញត្តិនៃមាត្រា ១៤ នៃ ICCPR។

54. ក្នុងករណីនេះ ជនសង្ស័យមិនត្រូវបានចោទជាផ្លូវការ ដូច្នេះហើយទើបគាត់មិនមែនជាភាគីមួយនៅក្នុងកិច្ចដំណើរការនីតិវិធីនេះទេ។ ដោយផ្អែកលើមូលដ្ឋាននេះហើយទើបសេចក្តីសម្រេចមុនៗរបស់ ស.ច.ស បានបដិសេធមិនព្រមផ្តល់ជូនជនសង្ស័យនូវលទ្ធភាពចូលពិនិត្យសំណុំរឿង និងសិទ្ធិផ្សេងទៀតរបស់ភាគីជាក់ស្តែងនៅក្នុងកិច្ចដំណើរការនីតិវិធី [49]។

55. ទោះបីយ៉ាងណា នៅក្នុងករណីនេះ ស.ច.ស.អ.ប បានសម្រេចជូនដំណឹងទៅ ជនដែលជាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទាក់ទងនឹងសំណុំរឿង ០០៤ អំពីឋានៈរបស់គាត់ជាជនសង្ស័យម្នាក់។ ដូច្នេះ នៅក្នុងសេចក្តីសម្រេចដដែលនេះ ជនសង្ស័យត្រូវបានជូនដំណឹងថា *"ដោយអនុលោមតាមវិធានផ្ទៃក្នុង របស់អ.វ.ត.ក [វិធាន ២១(១)(ឃ)] សិទ្ធិ និងការធានានៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងឋានៈជាជនសង្ស័យ រួមមានសិទ្ធិមានមេធាវីការពារខ្លួនតាមការជ្រើសរើសរបស់ខ្លួន សិទ្ធិមាន*

---

[47] គណៈកម្មាធិការសិទ្ធិមនុស្ស សម័យប្រជុំលើកទី ៩០ ទីក្រុងហ្សឺណែវ ថ្ងៃទី ៩ ដល់ ២៧ ខែ កក្កដា ឆ្នាំ ២០០៧ *យោបល់រួមលេខ ៣២* កថាខណ្ឌ ១។ យោបល់រួមនេះ ជំនួសយោបល់រួមលេខ ១៣ (សម័យប្រជុំលើកទី ២១) គេហទំព័រ៖ http://daccess-ods.un.org/access.nsf/Get?Open&DS=CCPR/C/GC/32&Lang=E (ចូលមើលចុងក្រោយនៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។).

[48] បន្ថែមពីលើនេះ មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលបញ្ចូលបទដ្ឋានទាំងនេះ គ្រាន់តែទទួលស្គាល់ជនទាំងនោះជា "ជនជាប់ចោទ"។

[49] សំណុំរឿង ០០៤ ឯកសារ A1/2 *ចម្លើយតបរបស់ ស.ច.ស ស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤* ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០៖ *"សិទ្ធិការពារក្តីអាចអនុវត្តបានយ៉ាងពេញលេញ (ហើយគោលការណ៍សមភាពនៃមធ្យោបាយតទល់រឿងក្តីត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួននៅពេលដែលជនម្នាក់ត្រូវបានចោទប្រកាន់ ហើយក្លាយជាភាគីនៃកិច្ចដំណើរការនីតិវិធី។ ប៉ុន្តែ ដរាបណាជនណាម្នាក់មិនត្រូវបានចោទប្រកាន់ជាផ្លូវការ សិទ្ធិរបស់ជននោះនៅមានកម្រិតនៅឡើយ។ នេះគឺជាករណីដែលអនុវត្តនៅគ្រប់ប្រព័ន្ធនីតិវិធីទាំងអស់"*។

*លទ្ធភាពទទួលបានឯកសារសំណុំរឿង(អនុវត្តស្របៀងគ្នាតាមវិធាន ៥៥(៦) វិធាន ៥៥(១)*[50] *និងវិធាន ៥៨ លើកលែងតែបញ្ញត្តិនៃវិធាន ៥៨(៦)នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក) និងសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី'*[51]។

56. ដូចនេះ នៅក្នុងកាលៈទេសៈពិសេសនៃករណីនេះ បញ្ហាគឺត្រូវកំណត់សិទ្ធិផ្សេងៗប្រសិនបើមានដែលជនដែលត្រូវបានជូនដំណឹងបែបនោះ មានសិទ្ធិទទួលបាន ។

**គ)លទ្ធផលនៃការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ**

57. ស.ច.ស.អ យល់ឃើញថា សេចក្តីសម្រេចស្តីពី*ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* បានផ្តល់ជូនជនសង្ស័យនូវសិទ្ធិដែលមានចែងយ៉ាងច្បាស់នៅក្នុងវិធានផ្ទៃក្នុង ២១(១)(ឃ)៖ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ ត្រូវទទួលបានដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន ត្រូវមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន និង នៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

58. ការអនុវត្តសិទ្ធិទាំងនេះ នៅក្នុងបរិបទពិសេសនៃការស៊ើបអង្កេតបច្ចុប្បន្ន គឺស្របទៅនឹងបទដ្ឋានអន្តរជាតិស្តីពីភាពយុត្តិធម៌។

59. ទោះបីយ៉ាងណា ស.ច.ស.អ កត់សម្គាល់ថា សេចក្តីសម្រេចស្តីពី*ការជូនដំណឹងអំពីសិទ្ធិ របស់ជនសង្ស័យ* បានផ្តល់ជូនជនសង្ស័យនូវសិទ្ធិបន្ថែមទៀត ដែលមិនមានបង្ហាញនៅក្នុងវិធានផ្ទៃក្នុង ២១ ដោយមិនបានផ្តល់មូលដ្ឋានច្បាប់សម្រាប់ការធ្វើដូច្នេះឡើយ។ ក្នុងកម្រិតដែលសេចក្តីសម្រេចនោះបានធ្វើដូច្នេះ គឺមិនទាន់ដល់ពេលដែលត្រូវធ្វើសេចក្តីសម្រេចណាមួយឡើយ នៅក្នុង **សេចក្តីសម្រេចនេះ** ហើយ ស.ច.ស.អ បដិសេធមិនព្រមធ្វើដូច្នេះឡើយ។

---

[50] បានកត់សម្គាល់ថា ឯកសារជាភាសាបារាំងនៃ*ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ(D110)* សំដៅលើវិធានផ្ទៃក្នុង ៥៥(១១) ខណៈដែលឯកសារជាភាសាអង់គ្លេស(ភាសាដើម) និងភាសាខ្មែរ សំដៅលើវិធានផ្ទៃក្នុង ៥៥(១) ។

[51] សំណុំរឿង ០០៤ ឯកសារ D110 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ។

## សិទ្ធិរបស់ជនក្រីក្រក្នុងការទទួលបានមេធាវីតាមជម្រើស

60. វិធានផ្ទៃក្នុង ២២(១) ចែងថា ជនណាដែលមានសិទ្ធិទទួលបានមេធាវី ក្រោមវិធានផ្ទៃក្នុង ត្រូវមានសិទ្ធិទទួលបានជំនួយពីមេធាវីជាតិ ឬមេធាវីបរទេសដោយសហការជាមួយមេធាវីជាតិតាមជម្រើសរបស់ខ្លួន [52]។

61. បន្ថែមពីលើនេះ ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទដែលក្រីក្រ មានសិទ្ធិទទួលបានតំណាងផ្នែកច្បាប់ ដោយ អ.វ.ត.ក ទទួលបន្ទុកចំណាយ អនុលោមតាមវិធានផ្ទៃក្នុង និងបទបញ្ជារដ្ឋបាលរបស់ អ.គ.ក [៥៣]។

62. ស.ច.ស.អ កត់សម្គាល់នៅត្រង់ចំណុចនេះថា អ.គ.ក បានកំណត់ថាជនសង្ស័យមានគុណវុឌ្ឍិទទួលជំនួយពីមេធាវី ដោយ អ.វ.ត.ក ទទួលបន្ទុកចំណាយ [54]។

## មេធាវីដែលមានឈ្មោះបញ្ចូលនៅក្នុងបញ្ជីមេធាវី ត្រូវតែមានគុណវុឌ្ឍិ

63. នៅក្នុងកាលៈទេសៈពិសេសនៃករណីនេះ ដោយកំណត់ថា ជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវីតាមជម្រើសរបស់ខ្លួន បញ្ហាចោទលើកឡើងថាតើ ចំណុចនេះ តម្រូវឱ្យ ឬក៏មិនតម្រូវឱ្យ ស.ច.ស អនុញ្ញាតតាមសំណើដែលបានស្នើនៅក្នុងសំណើស្តីពីសិទ្ធិក្នុងការមានមេធាវី "បង្គាប់ការិយាល័យរដ្ឋបាល "OA [ក.រ]" រួមទាំងអង្គភាពគាំពារការពារក្តី "DSS [អ.គ.ក]"រៀបចំកិច្ចសន្យាសេវាផ្លូវច្បាប់សម្រាប់លោក Richard Rogers ("Rogers") ក្នុង

[52] សំណុំរឿង ០០៤ ឯកសារ D111/2 *លិខិតពី អ.គ.ក ការចាត់តាំងលោក មុំ លុជ្ស ជាមេធាវីជាតិបណ្តោះអាសន្នសម្រាប់ជនសង្ស័យឈ្មោះ*[redacted]*នៅក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២។

[៥៣] វិធានផ្ទៃក្នុង ២២(១)(ខ) និង បទបញ្ជារដ្ឋបាលរបស់អ.គ.ក មាត្រា ១១ ។

[54] សំណុំរឿង ០០៤ ឯកសារ D111/2 *ការចាត់តាំងលោក មុំ លុជ្ស ជាមេធាវីកម្ពុជាបណ្តោះអាសន្នសម្រាប់ជនសង្ស័យឈ្មោះ*[redacted]*នៅក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២។ សំណុំរឿង ០០៤ ឯកសារ D111/2.1 *សំណើសុំ [ជួល]/ចាត់តាំងសហមេធាវី* ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២។

នាមជាមេធាវីអន្តរជាតិសម្រាប់ការពារក្ដីឱ្យជនសង្ស័យ"[៥៥] និង *"ពិនិត្យឡើងវិញនូវទង្វើរបស់លោក Rosandhaug និង លោក Endeley"*[៥៦]។

64. ទោះបីជាជនសង្ស័យមានសិទ្ធិទទួលបានមេធាវីតាមជម្រើសរបស់ខ្លួនយ៉ាងណាក៏ដោយ ក៏វិធានផ្ទៃក្នុង និងបទបញ្ជារដ្ឋបាល បង្ហាញពីនីតិវិធីផ្សេងៗក្នុងនោះ លក្ខណៈអាចទទួលយកជាមេធាវីតំណាងជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ ត្រូវបានកំណត់។

65. សមាសធាតុសំខាន់មួយនៃគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក គឺមានបំណងធានាថាជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ ទទួលបានតំណាងផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព។ សមាសធាតុនេះគឺថា មេធាវីដែលតំណាងជនទាំងនោះ បំពេញតាមបទដ្ឋានវិជ្ជាជីវៈដែលបានកំណត់យ៉ាងច្បាស់លាស់។ មេធាវីដែលមិនបំពេញតាមបទដ្ឋានទាំងនោះ គឺគ្មានសិទ្ធិអាចធ្វើជាមេធាវីបែបនោះបានឡើយ ។

66. វិធានផ្ទៃក្នុង ១១(២)(គ) តម្រូវឱ្យ អ.គ.ក រក្សាទុកបញ្ជីមេធាវីជាតិ និងបរទេសដែលមានសិទ្ធិតំណាងនៅចំពោះមុខ អ.វ.ត.ក។

67. បន្ថែមពីលើនេះ ទាក់ទងនឹងជនក្រីក្រ វិធានផ្ទៃក្នុង ១១(២)(ឃ)(ii) តម្រូវឱ្យអ.គ.ក ប្រមូលនិងរក្សាទុកដូចជាអនុបញ្ជីមេធាវីបរទេសដែលត្រូវបានទទួលស្គាល់នៅគណៈមេធាវីក្នុងរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ ហើយត្រូវបានចុះបញ្ជីនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយបំពេញតាមលក្ខណៈវិនិច្ឆ័យរបស់ អ.គ.ក ដូចមានចែងនៅក្នុងបទបញ្ជារដ្ឋបាល ដើម្បីការពារជនក្រីក្រនៅចំពោះមុខ អ.វ.ត.ក។

---

[៥៥] សំណុំរឿង ០០៤ ឯកសារ D122/2 *ញត្តិស្ដីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣។

[៥៦] សំណុំរឿង ០០៤ ឯកសារ D122/5 *សារណាបន្ថែមស្ដីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៣ ។

68. ដើម្បីសម្រេចតាមគោលបំណងនេះ អនុវិធាន ១.៥ នៃបទបញ្ជារដ្ឋបាល ចែងថា អ.គ.ក ត្រូវសម្រេចថាតើបេក្ខជនមាន ឬក៏មិនមានគុណវុឌ្ឍិត្រូវបញ្ចូលទៅក្នុងបញ្ជីមេធាវី ដោយពេញលេញ ឬដោយបណ្ដោះអាសន្ន។

69. ស.ច.ស.អ កត់សម្គាល់ទៅលើការអនុវត្តរបស់អ.គ.ក ក្នុងការបញ្ចូលទៅក្នុងបញ្ជីមេធាវីនូវឈ្មោះមេធាវីដែលមិនទាន់ចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា ដើម្បីចៀសវាងចំណាយមិនចាំបាច់ដោយសារសោហ៊ុយចុះបញ្ជីនៅគណៈមេធាវីកម្ពុជា [៥៧]។ ទាក់ទងនឹងការអនុវត្តផ្អែកលើកាលៈទេសៈជាក់ស្ដែងនេះ(ដែលភាគីដាក់សំណើ យកជាមូលដ្ឋានដើម្បីពន្យល់ពីការបញ្ចូលឈ្មោះលោក Rogers ទៅក្នុងបញ្ជីឈ្មោះដែលផ្ដល់ជូនជនសង្ស័យ)នោះ សូមទុកមួយឡែកសិនបញ្ហាថាតើការអនុវត្តបែបនេះរំលោភបំពានលើបទបញ្ជារដ្ឋបាលរបស់អ.គ.ក តាមវិធានផ្ទៃក្នុងឬអត់នោះ ប៉ុន្តែអ្វីដែលច្បាស់គឺថា ការបញ្ចូលឈ្មោះទៅក្នុងបញ្ជីមេធាវី ត្រូវពឹងផ្អែកលើលក្ខណវិនិច្ឆ័យសត្យានុម័តមួយចំនួនដែលត្រូវតែបំពេញ។

70. ជាពិសេស លក្ខណវិនិច្ឆ័យសម្រាប់បញ្ចូលឈ្មោះទៅក្នុងបញ្ជីមេធាវីរបស់អ.គ.ក ដើម្បីការពារជនក្រីក្រនៅចំពោះមុខ អ.វ.ត.ក តាមវិធានផ្ទៃក្នុង ១១(៤)(គ)(iii) និងបទបញ្ជារដ្ឋបាល២.២

[៥៧] សំណុំរឿង ០០៤ ឯកសារ D122/2 *ញត្តិស្ដីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១០៖ *"បន្ទាប់ពីបំពេញបែបបទតាមទម្លាប់អនុវត្តដែលមានស្រាប់នៅ អ.វ.ត.ក នោះ លោក Rogers មិនបានចុះឈ្មោះក្នុងបញ្ជីមេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា("BAKC") នាដំណាក់កាលនោះទេ។ ដោយសារគណៈមេធាវីកម្ពុជាកំណត់តម្លៃក្នុងការចុះឈ្មោះខ្ពស់ពេក ចាប់តាំងពីសំណុំរឿងទី ១ មក អង្គភាពគាំពារការពារក្ដីនៅតែរក្សាបញ្ជីឈ្មោះមេធាវី ដែលអង្គភាពគាំពារការពារក្ដី បានអនុម័តទុកមុន តែមិនទាន់បានចុះបញ្ជីនៅគណៈមេធាវីកកម្ពុជាទេ។ បញ្ជីរបស់អង្គភាពគាំពារការពារក្ដីនេះ តំណាងឱ្យក្រុមមេធាវីដែលជនសង្ស័យបានជ្រើសរើស។ បើតាមទម្លាប់អនុវត្តដែលមានស្រាប់ បន្ទាប់ពីសហមេធាវីបរទេសមួយរូបត្រូវបានជ្រើសរើស និងតែងតាំងរួចឱ្យកាន់ក្ដីហើយនោះ ពាក្យសុំចុះបញ្ជីរបស់មេធាវីរូបនោះនឹងត្រូវបញ្ជូនទៅគណៈមេធាវីកម្ពុជា។ នៅពេលចុះបញ្ជី មេធាវីបរទេសបានបំពេញបែបបទទាំងអស់រួចហើយ។ បន្ទាប់ពីបានជ្រើសរើសរួច តែមុនពេលស្បថចូលកាន់តំណែង សហមេធាវីបរទេសដែលត្រូវបានជ្រើសរើសនោះ ត្រូវចុះកិច្ចសន្យាជាទីប្រឹក្សាច្បាប់។ នៅពេលចុះបញ្ជីរួចហើយ កិច្ចសន្យានេះនឹងក្លាយជាកិច្ចសន្យាផ្ដល់សេវាផ្លូវច្បាប់ "អចិន្ត្រៃយ៍"។ នីតិវិធីនេះត្រូវតែអនុវត្តនៅគ្រប់ពេលនៃអាណត្តិការងារនៅ អ.វ.ត.ក នេះ តាំងពីសហមេធាវីដំបូងគេ គឺលោក Francois Roux មកម្ល៉េះ។ ចៅក្រមស៊ើបអង្កេត គណៈមេធាវីកម្ពុជា និងការិយាល័យរដ្ឋបាល បានគាំទ្រនីតិវិធីនេះដោយផ្ទាល់ផង ឬដោយប្រយោលផង"។*

(iii) គឺមានលក្ខខណ្ឌតម្រូវដូចជា មេធាវីបរទេសត្រូវមានបទពិសោធន៍ការងារយ៉ាងហោចណាស់ ១០ ឆ្នាំនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ក្នុងតួនាទីជាមេធាវី ជាចៅក្រម ឬព្រះរាជអាជ្ញា ឬតួនាទីផ្សេងទៀតមួយចំនួន។

71. បន្ថែមពីលើនេះ បទបញ្ជារដ្ឋបាល ៩ ចែងពីវិធានទាក់ទងនឹងទំនាស់ផលប្រយោជន៍ ពីព្រោះថា អត្ថិភាពទំនាស់ផលប្រយោជន៍ អាចបំផ្លាញប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ឬ ជនជាប់ចោទ។ យោងតាមមាត្រា ៩ នៃបទបញ្ជារដ្ឋបាលរបស់ អ.គ.ក៖

*"៩.១ សហមេធាវីមិនត្រូវចូលរួមក្នុងសកម្មភាពដែលមិនស្របជាមួយការបំពេញតួនាទីជាតំណាងផ្លូវច្បាប់របស់ជនជាប់ចោទឡើយ ។ ជាពិសេស សហមេធាវីមិនត្រូវស្វះស្វែងរក ឬទទួលសេចក្តីណែនាំពីរដ្ឋាភិបាលណាមួយទាក់ទងនឹងការតំណាងជនជាប់ចោទឡើយ ។*

*៩.២ សហមេធាវីត្រូវប្រុងប្រយ័ត្នគ្រប់យ៉ាងដើម្បីធានាថា មិនមានទំទាស់ផលប្រយោជន៍កើតឡើង។ ពួកគេត្រូវគិតពីផលប្រយោជន៍កូនក្តីមុនផលប្រយោជន៍របស់ខ្លួន ឬផលប្រយោជន៍របស់បុគ្គលណាម្នាក់ អង្គការ ឬរដ្ឋណាមួយ ដោយគោរពឲ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង បទបញ្ជារដ្ឋបាលទាំងនេះ និងក្រមសីលធម៌ដែលពួកគេជាប់កាតព្វកិច្ច។*

*៩.៣ នៅពេលមានទំនាស់ផលប្រយោជន៍កើតឡើង សហមេធាវីត្រូវជូនដំណឹងជាបន្ទាន់ដល់កូនក្តីដែលអាចរងផលប៉ះពាល់ អំពីអត្ថិភាពនៃទំនាស់ផលប្រយោជន៍ ហើយអាចដកខ្លួនចេញពីតំណាងកូនក្តីម្នាក់ ឬច្រើននាក់ ឬក៏ស្វែងរកការយល់ព្រមពីកូនក្តីដែលអាចរងផលប៉ះពាល់ គឺការយល់ព្រមដោយពេញលេញ និងធ្វើឡើងជាលាយលក្ខណ៍អក្សរដោយទទួលបានព័ត៌មាន"។*

72. យោងតាមមាត្រា ១.៧ នៃបទបញ្ជារដ្ឋបាលរបស់ អ.គ.ក បេក្ខជនដែលត្រូវបានបញ្ចូលឈ្មោះទៅក្នុងបញ្ជីមេធាវី ត្រូវបានដកចេញពីបញ្ជីវិញប្រសិនបើគាត់ លែងមានគុណវុឌ្ឍិដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្តន៍របស់អ.វ.ត.ក និងបទបញ្ជារដ្ឋបាល ព្រមទាំងច្បាប់

ព្រះរាជាណាចក្រកម្ពុជាស្តីពីលក្ខន្តិកៈគណៈមេធាវី និងបទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈច្បាប់ ដែលត្រូវបានទទួលស្គាល់[៥៨]។

## ការជ្រើសរើសរបស់ជនសង្ស័យយកមេធាវីចេញពីបញ្ជីមេធាវី ត្រូវតែធ្វើឡើងដោយទទួលបានព័ត៌មាន

73. វិធានផ្ទៃក្នុង ២២(១)(ខ) ចែងថា ជនក្រីក្រដែលមានសិទ្ធិទទួលបានការតំណាងផ្នែកច្បាប់ ក្រោមវិធានផ្ទៃក្នុង ត្រូវមានសិទ្ធិជ្រើសរើសមេធាវីដោយសេរីពីក្នុងចំណោមមេធាវីជាតិ និង អន្តរជាតិដែលមានក្នុងបញ្ជីដូចមានចែងក្នុងវិធានផ្ទៃក្នុង ១១.២(ឃ)។

74. មាត្រា៥.១ នៃបទបញ្ជារដ្ឋបាលរបស់អ.គ.ក តម្រូវថា ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទត្រូវផ្តល់ជូននូវបញ្ជីមេធាវី ព្រមជាមួយ*ព័ត៌មានគ្រប់គ្រាន់* ដើម្បីផ្តល់លទ្ធភាពឱ្យជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ធ្វើការជ្រើសរើសដោយទទួលបានព័ត៌មានទាក់ទងនឹងតំណាងផ្នែកច្បាប់។ ដើម្បីឱ្យមានប្រសិទ្ធភាព វិធាន និងបទបញ្ជាខាងលើ តម្រូវថា មានតែមេធាវីដែលគុណវុឌ្ឍិប៉ុណ្ណោះដែលមានឈ្មោះនៅក្នុងបញ្ជីមេធាវី។

75. អាស្រ័យហេតុនេះ ការខកខានមិនផ្តល់ព័ត៌មានដល់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ អំពីអង្គហេតុជាប់ពាក់ព័ន្ធទាំងអស់ទាក់ទងនឹងគុណវុឌ្ឍិរបស់មេធាវីនៅក្នុងបញ្ជី និងអំពីលទ្ធភាពទំនាស់ផលប្រយោជន៍ អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសមត្ថភាពរបស់ជនក្រីក្រក្នុងការជ្រើសរើសដោយទទួលបានព័ត៌មានទាក់ទងនឹងតំណាងផ្នែកច្បាប់ ដូច្នេះកាត់បន្ថយសិទ្ធិរបស់គាត់ក្នុងការទទួលបានជំនួយពីមេធាវីប្រកបដោយប្រសិទ្ធភាព។

## សិទ្ធិអំណាចរបស់ ស.ច.ស ក្នុងការទទួលស្គាល់ការជ្រើសរើសមេធាវីរបស់ជនសង្ស័យ

[៥៨] បន្ថែមពីលើនេះ យោងតាម មាត្រា ៧.៤ នៃបទបញ្ជារដ្ឋបាលរបស់ អ.គ.ក គឺ អ.វ.ត.ក អាចសម្រេចថា សហមេធាវីអស់សិទ្ធិក្នុងការការពារជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ។

76. សេរីភាពក្នុងការជ្រើសរើសមេធាវី គឺជាសិទ្ធិជាសារវ័ន្តដែលអាចត្រូវដាក់កំហិតបាន លុះត្រាតែនៅក្នុងកាលៈទេសៈមួយចំនួនដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់(ដូចមានចែងខាងលើសម្រាប់ អ.វ.ត.ក) ហើយអនុវត្តតាមដំណើរការដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់។

77. ទាក់ទងនឹងបញ្ហាបែបនេះ ស.ច.ស គ្មានតួនាទីអ្វីដែលត្រូវគិតឱ្យហួសពីការទទួលស្គាល់មេធាវីជាផ្លូវការនៅពេលដែលលក្ខខណ្ឌតម្រូវទាំងអស់ត្រូវបានបំពេញនោះឡើយ។ ទាំងច្បាប់បារាំង [59] និងច្បាប់កម្ពុជាស្តីពីគណៈមេធាវី និងក្រមសីលធម៌មេធាវី មិនបង្ហាញថាអនុញ្ញាតឱ្យសមត្ថកិច្ចតុលាការមានសិទ្ធិសម្រេចថាតើ សេរីភាពរបស់ជនសង្ស័យក្នុងការជ្រើសរើសមេធាវីរបស់ខ្លួន គួរត្រូវដាក់កំហិត ឬអត់នោះឡើយ[60]។

---

[59] JurisClasseur Procédure pénale ; App. Art. 53 à 73, Fasc. 20 : Garde A Vue, Jacques Leroy, Professeur agrégé des facultés de droit, កថាខណ្ឌ ១៦៤ នៅ៖: http://www.lexisnexis.fr/lnjcpro, ចូលមើលចុងក្រោយបំផុតនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣។ មាត្រា ៦៣-៣-១,al.5 ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង (réd. L. 14 avr. 2011)"។

[60] ក្រមសីលធម៌សម្រាប់មេធាវីដែលមានអាជ្ញាប័ណ្ណពី គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៤៖ ទំនាក់ទំនងរវាងមេធាវី និងកូនក្តី មាត្រា ១៩៖ កូនក្តីច្រើននាក់ គេហទំព័រ៖ http://en.bakc.org.kh/Law_For_Lawyer/Code%20of%20Ethics_En.pdf, ចូលមើលចុងក្រោយនៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣ "*ប្រសិនបើមេធាវីត្រូវបានជួលដោយកូនក្តីច្រើននាក់សម្រាប់រឿងក្តី ឬដំណើរការដូចគ្នា មេធាវីត្រូវបានហាមឃាត់មិនឱ្យលម្អៀងដើម្បីប្រយោជន៍របស់កូនក្តីណាម្នាក់នោះឡើយ។ មេធាវីជូនដំណឹងភាគីផ្សេងៗ*"*អំពីស្ថានភាពនេះ។ មេធាវី អាចមិនផ្តល់យោបល់ ជំនួយ ធ្វើជាតំណាង ឬការពារក្តីឱ្យភាគីច្រើនផ្សេងគ្នាបានឡើយប្រសិនមានទំនាស់ផលប្រយោជន៍កើតឡើងរវាងភាគីទាំងនោះ។ ប្រសិនបើទំនាស់បែបនេះកើតឡើងនៅពេលដែលមេធាវីនោះ គឺជា ឬធ្លាប់ជាមេធាវីឱ្យភាគីច្រើនផ្សេងគ្នា មេធាវីនោះ មិនអាចតំណាងឱ្យប្រយោជន៍របស់ភាគីណាមួយបានឡើយ ហើយនៅតែស្ថិតនៅក្រោមកាតព្វកិច្ចដាច់ខាតមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ការប្រុងប្រយ័ត្ន ឬការរក្សាការសម្ងាត់ឡើយ*"។
ក្នុងករណីគ្មានលំនាំផ្ទាល់ពីច្បាប់កម្ពុជា អាចកត់សម្គាល់ថា ក្រោមច្បាប់បារាំង ជាទូទៅ គឺប្រធានគណៈមេធាវីដែលជាអ្នកដោះស្រាយបញ្ហាទំនាស់ផលប្រយោជន៍ មិនថាបញ្ហានេះត្រូវលើកឡើងដោយភាគីណាមួយនៅក្នុងកិច្ចដំណើរការនីតិវិធី ឬក៏ដោយសមត្ថកិច្ចតុលាការឡើយ (មាត្រា ២១ *Loi n° 71-1130 du 31 décembre 1971 Portant réforme de certaines professions judiciaires et juridiques*)។

[61] នៅក្នុងករណីបច្ចុប្បន្ន ភាគីដាក់សំណើ ហាក់ដូចជាមិនដាក់សំណើដើម្បីអនុវត្តសិទ្ធិប្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងសេចក្តីសម្រេចរបស់ អ.គ.ក ដែលបដិសេធសំណើរបស់លោក Rogers សុំបញ្ចូលទៅក្នុងបញ្ជីសហមេធាវីបរទេសរបស់ អ.គ.ក ដែលមានសិទ្ធិតំណាងកូនក្តីនៅចំពោះមុខ អ.វ.ត.ក។ ភាគីដាក់សំណើ ហាក់ដូចជាព្យាយាមដោះស្រាយបញ្ហានេះវិញ ដំបូងតាមរយៈ ចៅក្រមរដ្ឋបាលរបស់អង្គការសហប្រជាជាតិ ("UNAJ") បន្ទាប់មកតាមរយៈដាក់*ញត្តិស្តីពីសិទ្ធិក្នុងការមានមេធាវី*និង*សារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី*ផ្ញើជូន ស.ច.ស។

78. ក្រោមវិធានផ្ទៃក្នុង តួនាទីក្នុងការសម្រេចថាតើសេរីភាពក្នុងការជ្រើសរើសមេធាវីត្រូវដាក់កំហិត ឬអត់នោះ គឺមានបង្ហាញរួមគ្នាតាមរយៈគណៈមេធាវីកម្ពុជា និងអង្គភាពផ្ទៃក្នុងរបស់ អ.វ.ត.ក គឺ អ.គ.ក ។ គណៈមេធាវីកម្ពុជា ទទួលខុសត្រូវដូចជា សម្រេចថាតើលក្ខណវិនិច្ឆ័យសម្រាប់ការពារជនក្រីក្រ ត្រូវបានបំពេញឬអត់ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ១១(៤)។ បន្ថែមពីលើនេះទៀត មាត្រា ៩ នៃបទបញ្ជារដ្ឋបាល ចែងថា បញ្ហាទំនាស់ផលប្រយោជន៍ត្រូវសម្រេចដោយ អ.គ.ក។

79. បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចរបស់ស្ថាប័នទាំងនេះ ត្រូវធ្វើទៅអង្គបុរេជំនុំជម្រះរបស់ អ.វ.ត.ក ក្រោមវិធានផ្ទៃក្នុង ១១(៥) [61] និង ២២(១)(ច) [62]។ យោងតាមវិធាន ១១(៥)៖ *"មេធាវី ឬជំនួយការរបស់ខ្លួនដែលពាក្យសុំចុះឈ្មោះរបស់ពួកគេសម្រាប់ការពារជនក្រីក្រ ដូចមានចែងនៅក្នុងអនុវិធាន ចំណុច ២(ឃ) និង (ឈ)ខាងលើ ត្រូវបានបដិសេធ ឬមិនត្រូវបានពិនិត្យក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យដោយអង្គភាពគាំពារការពារក្ដី ឬត្រូវបានលុបឈ្មោះចេញពីបញ្ជី អាចប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃទទួលសេចក្ដីជូនដំណឹងពីសេចក្ដីសម្រេចរបស់ប្រធានអង្គភាពគាំពារការពារក្ដី ឬក្រោយរយៈពេល ៣០(សាមសិប)ថ្ងៃកន្លងផុត តាមករណីសមស្រប។ សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះបិទផ្លូវតវ៉ា។(...)*។

[61] នៅក្នុងករណីបច្ចុប្បន្ន ភាគីដាក់សំណើ ហាក់ដូចជាមិនដាក់សំណើដើម្បីអនុវត្តសិទ្ធិប្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងសេចក្ដីសម្រេចរបស់ អ.គ.ក ដែលបដិសេធសំណើរបស់លោក Rogers សុំបញ្ចូលទៅក្នុងបញ្ជីសហមេធាវីបរទេសរបស់ អ.គ.ក ដែលមានសិទ្ធិតំណាងកូនក្ដីនៅចំពោះមុខ អ.វ.ត.ក។ ភាគីដាក់សំណើ ហាក់ដូចជាព្យាយាមដោះស្រាយបញ្ហានេះវិញ ដំបូងតាមរយៈ ចៅក្រមរដ្ឋបាលរបស់អង្គការសហប្រជាជាតិ ("UNAJ") បន្ទាប់មកតាមរយៈដាក់*ញត្តិស្ដីពីសិទ្ធិក្នុងការមានមេធាវី*និង*សារណាបន្ថែមស្ដីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី*ផ្ញើជូន ស.ច.ស។

[62] វិធានផ្ទៃក្នុង ២២(១)(ច) ទាក់ទងនឹងគណៈមេធាវីកម្ពុជាក្នុងការបដិសេធមិនចុះបញ្ជីមេធាវី គឺមិនពាក់ព័ន្ធនឹងកាលៈទេសៈនៃករណីនេះឡើយ។

80. ដោយផ្អែកលើមូលដ្ឋានទាំងនេះ ស.ច.ស មិនមានយុត្តាធិការត្រួតពិនិត្យឡើងវិញទៅលើកទង្វើរបស់ប្រធាន អ.គ.ក និង អ.ប.គ.រ ឬក៏បង្គាប់ឱ្យការិយាល័យរដ្ឋបាល ចេញកិច្ចសន្យាការងារជូនលោក Rogers ដែរ។

## ការត្រួតពិនិត្យឡើងវិញទៅលើ*ដីកាសម្រេចទទួលស្គាល់*

81. ទោះបីយ៉ាងណា ភាគីដាក់សំណើ បានយក*ញត្តិស្តីពីសិទ្ធិក្នុងការមានមេធាវី* និង*សារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ដែលត្រូវបានដាក់ជូន ស.ច.ស ដោយផ្អែកលើមូលដ្ឋានដែលថា ស.ច.ស.អ.ប បានចេញ*ដីកាសម្រេចទទួលស្គាល់*រួចហើយទាក់ទងនឹងលោក Rogers។

82. ជាធម្មតា លក្ខខណ្ឌតម្រូវផ្លូវការសម្រាប់ទទួលស្គាល់នឹងត្រូវបំពេញតាមរយៈការបញ្ជាក់ថា អ.គ.ក បានជូនដំណឹង ស.ច.ស ថា មេធាវីបំពេញតាមលក្ខខណ្ឌតម្រូវទាំងអស់ដូចបានកំណត់ដោយវិធានផ្ទៃក្នុង និងបទបញ្ជារបស់អង្គភាពគាំពារការពារក្តី។ ដូច្នេះ ស.ច.ស នឹងកំណត់ការត្រួតពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចរបស់ ស.ច.ស.អ.ប ទៅត្រឹមបញ្ហាតវ៉ាជាប់ពាក់ព័ន្ធ ដោយផ្អែកលើមូលដ្ឋាននៃលក្ខណវិនិច្ឆ័យសត្យានុម័ត ដូចជា ការខកខានមិនបានទទួលស្គាល់ជាមុននៅគណៈមេធាវីកម្ពុជា ការខកខានមិនបានបំពេញលក្ខណវិនិច្ឆ័យអំពីបទពិសោធន៍ជាប់ពាក់ព័ន្ធ និងអត្ថិភាពទំនាស់ផលប្រយោជន៍[63]។

83. នៅក្នុងករណីបច្ចុប្បន្ននេះ ភាគីដាក់សំណើ បញ្ជាក់ថា លោក Rogers ត្រូវបានបញ្ចូលទៅក្នុងបញ្ជីមេធាវីដែលបានផ្តល់ជូនទៅជនសង្ស័យ។ នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២ ស.ច.ស.អ.ប បានចេញ*ដីកាសម្រេចទទួលស្គាល់* ក្នុងនោះ គាត់បានប្រកាសថា លោក Rogers "*ត្រូវបានជនសង្ស័យជ្រើសរើស និងជួលជាមេធាវី យ៉ាងត្រឹមត្រូវ*" និង បានបង្គាប់

---

[63] Cour d'appel de Pau, Chambre 1, 14 Janvier 1998, Numéro JurisData : 1998-970294 ; [ត្រូវបានបានបញ្ជាក់ដោយសេចក្តីសម្រេចរបស់តុលាការបារាំង Cour de Cassation, Chambre civile 1, 27 mars 2001, numéro de pourvoi 98-16508].

ដូចជា ឲ្យការិយាល័យរដ្ឋបាល រួមទាំង អ.គ.ក ទទួលស្គាល់ការចាត់តាំង លោក Rogers លុះត្រាតែអង្គជំនុំជម្រះ/សមត្ថកិច្ចតុលាការសមស្រប ដកការចាត់តាំងរបស់គាត់"[64]។

84. ទោះបីយ៉ាងណា អ.គ.ក ហាក់ដូចជាមិនបានបញ្ជាក់ជូន ស.ច.ស.អ.ប ជាផ្លូវការថា លោក Rogers បានបំពេញតាមលក្ខខណ្ឌតម្រូវទាំងអស់ដើម្បីទទួលស្គាល់ជាមេធាវីបរទេសតំណាងជនសង្ស័យ[65]។ ក្រោយពីការចាកចេញរបស់[redacted]មន្ត្រីទទួលបន្ទុក អ.គ.ក មក លោក Isaac Endeley ប្រធានថ្មីនៃអ.គ.ក បានសន្និដ្ឋានថា លោក Rogers មិនមានសិទ្ធិត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីមេធាវីបរទេសរបស់ អ.គ.ក ឡើយដោយសារមូលហេតុដូចខាងក្រោម[៦៦]៖

> *១. លោក Rogers មិនមានបទពិសោធន៍ដែលតម្រូវឲ្យមានក្រោមវិធានផ្ទៃក្នុង ១១(៤)*
>
> *២.អត្ថិភាពនៃទំនាស់ផលប្រយោជន៍រវាងអតីតតំណែងរបស់លោក Rogers ជាប្រធាន អ.គ.ក និងគោលបំណងរបស់គាត់ចង់ក្លាយជាសហមេធាវីការពារក្តីនៅ អ.វ.ត.ក និង*
>
> *៣. ទំនាស់ផលប្រយោជន៍នៃក្រមសីលធម៌ ដែលកើតចេញពីទំនាក់ទំនងរបស់លោក Rogers ជាមួយនឹងអតីតមន្ត្រីទទួលបន្ទុក*[redacted]

---

[៦៤] សំណុំរឿង ០០៤ ឯកសារ D111/5 *ដីកាសម្រេចទទួលស្គាល់មេធាវី* ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២។

[៦៥] នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ អតីតមន្ត្រីទទួលបន្ទុក អ.គ.ក [redacted] បានជូនដំណឹង សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ថា ជនសង្ស័យបានជ្រើសរើស លោក មុំ លុជ្ស និងលោក Rogers ជាសហមេធាវីរបស់គាត់។ ទោះបីយ៉ាងណា ទាក់ទងនឹងលោក Rogers គាត់បានជូនដំណឹង ស.ច.ស ថា " *ជាបឋម អ.គ.ក កំពុងស្នើសុំកិច្ចសន្យាប្រឹក្សាផ្នែកច្បាប់សម្រាប់មេធាវីរូបនេះ ដោយរង់ចាំគាត់ចូលជាសមាជិកនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា*"។ សំណុំរឿង ០០៤ ឯកសារ D111/2 *ការចាត់តាំងលោក មុំ លុជ្ស ជាមេធាវីជាតិបណ្តោះអាសន្នសម្រាប់ជនសង្ស័យឈ្មោះ*[redacted]*នៅក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០១២ កថាខណ្ឌ ៧ និង ៨។

[៦៦] សំណុំរឿង ០០៤ ឯកសារ D122/2.1.50 *លិខិតពី Isaac Enderly ប្រធាន អ.គ.ក ជូនចំពោះលោក Richard Rogers* ចុះថ្ងៃទី ៣០ ខែ ឧសភា (លិខិតរបស់ អ.គ.ក)។ ស.ច.ស.អ កត់សម្គាល់ថា អនុវិធាន ១.៧ នៃបទបញ្ជារដ្ឋបាល ផ្តល់សិទ្ធិឲ្យ អ.គ.ក ចេញបេក្ខជនចេញពីបញ្ជីមេធាវី ក្នុងករណីដែលគាត់លែងមានគុណវុឌ្ឍិដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង៖ បទបញ្ជារដ្ឋបាល ៧.៤៖ "*ការបណ្តេញសហមេធាវី: អង្គជំនុំជម្រះវិសាមញ្ញអាចសម្រេចថា សហមេធាវីអស់សិទ្ធិក្នុងការការពារជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទនៅអង្គជំនុំជម្រះវិសាមញ្ញ*"។

[redacted]

85. បន្ថែមលើនេះទៀត ទោះបីជាសន្មតថាការអនុលោមតាមការអនុវត្តរបស់អ.ត.ក មិនតម្រូវឱ្យមេធាវីចុះបញ្ជីនៅគណៈមេធាវីកម្ពុជានៅពេលដែលជនសង្ស័យបានជ្រើសរើសលោក Rogers ជាមេធាវីបរទេសរបស់ខ្លួនយ៉ាងណាក៏ដោយ ក៏លោក Rogers នៅមិនទាន់ស្បថចូលជាសមាជិកនៃគណៈមេធាវីកម្ពុជា នៅពេលដែលចេញ*ដីកាសម្រេចទទួលស្គាល់* ហើយមិនគួរត្រូវបានទទួលស្គាល់ឡើយរហូតទាល់តែលក្ខខណ្ឌតម្រូវទាំងអស់ត្រូវបានបំពេញទាំងស្រុង គឺមានន័យថា ក្រោយពេលដែលគាត់បានស្បថចូលកាន់តំណាងនៅសាលាឧទ្ធរណ៍របស់ប្រទេសកម្ពុជា នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២ [១៧]។

86. អាស្រ័យហេតុនេះ ស.ច.ស.អ យល់ឃើញថា នៅពេលដែល*ដីកាសម្រេចទទួលស្គាល់*ត្រូវបានចេញនៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២ ស.ច.ស.អ.ប មិនបានដឹងថា លោក Rogers អាចមិនមានបទពិសោធន៍ផ្នែកច្បាប់ជាប់ពាក់ព័ន្ធគ្រប់គ្រាន់ដើម្បីតំណាងជនក្រីក្រនៅចំពោះមុខ អ.វ.ត.ក ហើយអាចមានទំនាស់ផលប្រយោជន៍ទាក់ទងនឹងការតំណាងជនសង្ស័យ។ បន្ថែមពីលើនេះទៀត លោក Rogers មិនទាន់បានស្បថចូលកាន់តំណែងនៅពេលដែលចេញដីកាសម្រេចទទួលស្គាល់។ វិការៈទាំងនេះធ្វើឱ្យ*ដីកាសម្រេចទទួលស្គាល់* អស់សុពលភាព។

87. ស.ច.ស.អ រំឭកថា ប្រសិនបើបញ្ជីឈ្មោះមេធាវីត្រូវបានផ្តល់ជូនទៅជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ ដោយមានឈ្មោះមេធាវីដែលមិនអាចបំពេញគុណវុឌ្ឍិដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ១១(៤)(គ)(iii) និងបទបញ្ជារដ្ឋបាល ២.២ (iii) ហើយទាក់ទងនឹងមេធាវីបែបនេះ អាចមានទំនាស់ផលប្រយោជន៍ គឺប៉ះពាល់ដល់សមត្ថភាពរបស់ជនសង្ស័យ ជនត្រូវ

---

[១៧] ស.ច.ស.អ កត់សម្គាល់ថា នេះគឺជានីតិវិធីដែល លោក Goran Sluiter បានអនុវត្តតាម ហើយ អ.ត.ក បានជូនដំណឹង ស.ច.ស អំពីការតែងតាំងរបស់គាត់ បន្ទាប់ពីគាត់បានស្បថចូលកាន់តំណែងនៅថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១២៖ សំណុំរឿង 00៤ ឯកសារ D111/8 *លិខិតពីប្រធាន អ.ត.ក* ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១២។

ចោទ ឬជនជាប់ចោទក្នុងការធ្វើសេចក្តីសម្រេចដោយទទួលបានព័ត៌មានស្តីពីការជ្រើសរើសមេធាវី។

88. ដោយពិចារណាទៅលើកាលៈទេសៈអង្គហេតុជាក់ស្តែងចាប់តាំងពីមានសេចក្តីសម្រេចមុននេះ ស.ច.ស.អ មិនស្ថិតនៅក្នុងតួនាទីមួយដែលត្រូវសម្រេចថាតើឥឡូវនេះ លោក Rogers បាន ឬមិនបានបំពេញតាមលក្ខខណ្ឌតម្រូវទាំងអស់សម្រាប់ចូលក្នុងបញ្ជីមេធាវីដែលត្រូវបានទទួលស្គាល់ ដើម្បីការពារសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក ។

## ភាពយុត្តិធម៌តាមនីតិវិធី

89. *ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចោទថា ប្រធាន អ.គ.ក ខកខានមិនបានអនុវត្តតាមភាពយុត្តិធម៌តាមនីតិវិធី ដោយមិនបានផ្តល់ជូនជនសង្ស័យនូវសេចក្តីសង្ខេបអំពីភស្តុតាងគាំទ្រសេចក្តីសន្និដ្ឋានរបស់គាត់ទាក់ទងនឹងទំនាស់ផលប្រយោជន៍ ទំនាស់ក្រមសីលធម៌ និងកង្វះបទពិសោធន៍ដើម្បីផ្តល់ឱកាសជូនលោក Rogers ឱ្យផ្ញើឯកសារភស្តុតាងទាក់ទងនឹងបញ្ហាទាំងនេះ។

90. ស.ច.ស.អ កត់សម្គាល់ថា វិធានផ្ទៃក្នុង ១១(៤)(ក) តម្រូវថា ការបញ្ចូលឈ្មោះចូលទៅក្នុងបញ្ជីមេធាវីរបស់អ.គ.ក ដើម្បីការពារជនក្រីក្រនៅចំពោះមុខ អ.វ.ត.ក ត្រូវមានភាពយុត្តិធម៌ តម្លាភាព និងឆាប់រហ័ស។

## ការចោទប្រកាន់អំពីការប៉ះពាល់ដល់ជនសង្ស័យ

91. វិធានផ្ទៃក្នុង ២១(១) តម្រូវថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្តន៍ និងបទបញ្ញារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ។

00910712



92. ជាទូទៅ បញ្ហារដ្ឋបាលមិនមានលក្ខណៈដែលត្រូវសម្រេចដោយ ស.ច.ស ឡើយប្រសិនបើមិនអាចបង្ហាញថា បញ្ហានោះធ្វើឱ្យមានការបដិសេធមិនទទួលបានសិទ្ធិប្រកបដោយប្រសិទ្ធភាពសម្រាប់ភាគីនានា[៦៨]។

93. យោងតាម*ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* (កថាខណ្ឌ ១០៣)របស់ភាគីដាក់សំណើ គឺថា លោក មុំ លុជ្ស ខ្វះបទពិសោធន៍ខាងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ខណៈដែលលោក Goran Sluiter មានបទពិសោធន៍ខាងផ្នែកនេះ[៦៩]។ ដោយពិចារណាទៅលើកាលៈទេសៈទាំងនេះ នៅក្នុង**សេចក្តីសម្រេចនេះ** មិនចាំបាច់ត្រូវដោះស្រាយបញ្ហាថាតើជនសង្ស័យគួរ ឬមិនគួរត្រូវផ្តល់ជូននូវសិទ្ធិមានសហមេធាវីទាំងពីរនេះនោះឡើយ។

94. ភាគីដាក់សំណើ បានបញ្ជាក់ថា ពួកគាត់នឹងមិនប្រឆាំងនឹងសេចក្តីសម្រេចរបស់ ស.ច.ស ដែលបង្គាប់ឱ្យបញ្ជូន *ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ទៅប្រធានអ.គ.ក និង អ.ប.ក.វ (កថាខណ្ឌ ៧ នៃញត្តិខាងលើនេះ)។

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញថាៈ**

95. នៅក្នុងកាលៈទេសៈពិសេសនៃករណីនេះ ស.ច.ស.អ.ប បានកំណត់ថា បុគ្គលម្នាក់ដែលត្រូវបានកំណត់សញ្ញាណនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ

---

[៦៨] Artico ទល់នឹង អ៊ីតាលី សំណើលេខ No 6694/74, 13 May 1980 កថាខណ្ឌ ៣៣។ សំណុំរឿង ០០២ ឯកសារលេខ D390/1/2/4 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារឆ្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦* កថាខណ្ឌ ១៣។

[៦៩] សំណុំរឿង ០០៤ ឯកសារ D111/8 *ការចាត់តាំងមេធាវីអន្តរជាតិ* ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១២។ សំណុំរឿង ០០៤ ឯកសារ D122/2 *ញត្តិស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១០៣។

ស៊ើបសួរបន្ថែមរបស់ ស.ព.រ គឺជាជនសង្ស័យ ដូច្នេះ ជននេះមានសិទ្ធិទទួលបានសិទ្ធិដែលមានចែងនៅក្នុងមាត្រា ២១(១)(ឃ) [៧០]។

96. វិធានផ្ទៃក្នុង ២១ តម្រូវថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្តន៍ និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ។

97. ប្រធាន អ.គ.ក មានការទទួលខុសត្រូវរក្សាទុកបញ្ជីមេធាវីដែលមានសិទ្ធិតំណាងជនក្រីក្រនៅចំពោះមុខអ.វ.ត.ក ដោយតុលាការទទួលបន្ទុកចំណាយ ហើយទទួលខុសត្រូវធានាថាមេធាវីទាំងនោះត្រូវចុះបញ្ជីនៅគណៈមេធាវីកម្ពុជា និងបំពេញតាមលក្ខណៈវិនិច្ឆ័យរបស់ អ.គ.ក ដូចមានចែងនៅក្នុងបទបញ្ជារដ្ឋបាលរបស់ខ្លួន។

98. មិនមានការជំទាស់ថា លោក មុំ លុជ្ស មិនអាចមានសិទ្ធិធ្វើជាមេធាវីកម្ពុជាតំណាងជនសង្ស័យឡើយ។

99. គ្មានសំអាងហេតុដែលត្រូវលើកឡើងពីបញ្ហាលទ្ធភាពទំនាស់ផលប្រយោជន៍ ឬបញ្ហារក្សាការសម្ងាត់ឡើយចំពោះលោក Goran Sluiter បន្ទាប់ពី ក.ស.ច.ស បានធ្វើការត្រួតពិនិត្យឡើងវិញទៅលើស្ថានភាពរបស់គាត់ ក្នុងនាមជាអតីតទីប្រឹក្សាប្រចាំនៅក្រុមការពារក្តីមួយក្រុមនៅក្នុងសំណុំរឿង ០០២ និងឯកសារស្រាវជ្រាវសិក្សាពីមុនដែលត្រូវបានផ្តល់ជូន ក.ស.ច.ស ក្រោមការគ្រប់គ្រងរបស់គាត់ ។

100. មិនមានការជំទាស់ថា លោក Goran Sluiter មិនអាចមានសិទ្ធិធ្វើជាមេធាវីបរទេសតំណាងជនសង្ស័យឡើយ។

101. ក្នុងករណីដែល មេធាវីម្នាក់មានឈ្មោះនៅក្នុងបញ្ជីមេធាវីដែលមានសិទ្ធិតំណាងជនសង្ស័យជាជនក្រីក្រ ប៉ុន្តែមិនបានបំពេញតាមគុណវុឌ្ឍិដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង សេចក្តីណែនាំ

---

[៧០] ក្នុងកម្រិតដែល *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ*ចេញដោយ ស.ច.ស.អ.ប បានផ្តល់ឲ្យជនសង្ស័យនូវសិទ្ធិ ហួសពីសិទ្ធិដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ២១(១)(ឃ)នោះ សុពលភាពនៃការផ្តល់សិទ្ធិបែបនេះ នឹងក្លាយជាកម្មវត្ថុនៃសេចក្តីសម្រេចនាពេលអនាគត។

អនុវត្តន៍របស់អ.វ.ត.ក និងបទបញ្ជារដ្ឋបាល នោះ ប្រធាន អ.គ.ក មានកាតព្វកិច្ចដកមេធាវីនោះចេញពីបញ្ជីមេធាវី។

102. ដោយផ្អែកលើការត្រួតពិនិត្យឡើងវិញលើគុណវុឌ្ឍិរបស់លោក Roggers នោះ លោក Isaac Endeley បានសន្និដ្ឋានថា លោក Rogers មិនមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីតំណាងជនសង្ស័យ ហើយមានទំនាស់ផលប្រយោជន៍ដែលមិនអាចឲ្យមានគុណវុឌ្ឍិគ្រប់គ្រាន់។

103. នៅពេលដែល ស.ច.ស.អ.ប បានចេញ*ដីកាសម្រេចទទួលស្គាល់* ហើយប្រកាសថា លោក Rogers ត្រូវបាន *"ជ្រើសរើស និងជួលជាមេធាវីយ៉ាងត្រឹមត្រូវ"* គឺគាត់មិនដឹងអំពីកត្តាផ្សេងៗ ដែលបានបង្ហាញនៅក្នុងលិខិតរបស់ អ.គ.ក។

104. កត្តាផ្សេងៗដែលបានបង្ហាញនៅក្នុងលិខិតរបស់ អ.គ.ក អាចប៉ះពាល់ដល់ប្រយោជន៍របស់ជនសង្ស័យក្នុងការទទួលបានតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព នៅចំពោះមុខ អ.វ.ត.ក ហើយអាចផ្ទុយពីប្រយោជន៍យុត្តិធម៌។

105. លោក Rogers ជំទាស់ទៅនឹងកត្តាដែលមិនអាចឲ្យមានគុណវុឌ្ឍិគ្រប់គ្រាន់ដូចបានបង្ហាញនៅក្នុងលិខិតរបស់ អ.គ.ក។

106. គោលការណ៍យុត្តិធម៌ តម្រូវថា លោក Rogers ត្រូវផ្តល់ជូននូវឱកាសបង្ហាញភស្តុតាងជូន អ.គ.ក ដែលនឹងបញ្ជាក់ពីគុណវុឌ្ឍិរបស់គាត់អាចតំណាងជនក្រីក្រ នៅចំពោះមុខ អ.វ.ត.ក ដោយ UNAKRT ទទួលបន្ទុកចំណាយ។

107. ស.ច.ស មិនមានយុត្តាធិការសម្រេចទៅលើជម្លោះទាក់ទងនឹងថាតើ មេធាវីគួរត្រូវដាក់បញ្ចូលទៅក្នុងបញ្ជីមេធាវីរបស់ អ.គ.ក ឬអត់នោះឡើយ។

**ដោយផ្អែកលើសំអាងហេតុខាងនេះ ខ្ញុំ MARK B. HARMON ៖**

108. **បញ្ជាក់ពី***ដីកាសម្រេចទទួលស្គាល់* ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២ ទាក់ទងនឹងលោក មុំ លុផ្សា។

109. **ទទួលស្គាល់** លោក Goran Sluiter ជាសហមេធាវីបរទេសតំណាងជនសង្ស័យ។

110. **លុបចោល** *ដីកាសម្រេចទទួលស្គាល់* ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២ ទាក់ទងនឹង លោក Richard Rogers ។

111. **បញ្ជូន** បញ្ហានេះត្រឡប់ទៅ អ.គ.ក ដើម្បីពិចារណាឡើងវិញទៅលើលក្ខណៈគុណវុឌ្ឍិដែលអាចបញ្ចូល លោក Richard Rogers ទៅក្នុងបញ្ជីមេធាវីបរទេសរបស់ អ.គ.ក។

112. **ស្នើ** លោក Richard Rogers បញ្ជូនឯកសារភស្តុតាងមក អ.គ.ក ទាក់ទងនឹងកត្តាចំនួនបី ដូចបានបង្ហាញនៅក្នុងលិខិតរបស់ អ.គ.ក ដែលធ្វើឱ្យគាត់មិនមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការបញ្ចូលទៅក្នុងបញ្ជីមេធាវី ក្នុងរយៈពេល ១០(ដប់ថ្ងៃ)បន្ទាប់ពីថ្ងៃចេញ**សេចក្ដីសម្រេច**នេះ។

113. **សម្រេច** ផ្ដល់ឯកសារថតចម្លងមួយច្បាប់នៃ *ញត្តិ សារណាបន្ថែម* និង**សេចក្ដីសម្រេច**នេះជូនប្រធាន អ.គ.ក និង អ.ប.ក.វ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០១៣

**Mark B. Harmon**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co-Investigating Judge**
**Co-juge d'instruction international**